**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | សហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-Nov-21, 14:43
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ ក.ស.ច.ស: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំឲ្យ បញ្ចប់ បោះត្រា និង បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**អ្នកទទួលឯកសារ:**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

**សហមេធាវី យឹម ទិត្យ:**
លោក សូ មូហ្សេន្នី
Suzana TOMANOVIĆ

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុង**
**សំណុំរឿង ០០៤**

## I. សេចក្ដីផ្ដើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ”) សុំឆ្លើយតបទៅនឹងសំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់ បោះត្រា និងបញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ[1]។ ដូចបានរៀបរាប់លម្អិតខាងក្រោម សំណើនេះមិនអាចទទួលយកបានទេ ហើយប្រសិនបើត្រូវបានទទួលយកនោះ សំណើនេះខកខាន មិនបានបង្ហាញថា ការបញ្ចប់សំណុំរឿង ០០៤ គឺជាការត្រឹមត្រូវនៅក្នុងកាលៈទេសៈនៃរឿងក្ដីនេះ។ ហេតុដូច្នេះ សំណើនេះគួរតែត្រូវច្រានចោល។ ជាងនេះទៀត ផ្ទុយពីការសម្រេចបាននូវកម្រិតណាមួយនៃភាពស្ថាពរ សេចក្ដីសម្រេចពី ស.ច.ស នឹងត្រូវប្ដឹងឧទ្ធរណ៍ដោយ ស.ព.អ ដែលនាំឱ្យមានវដ្តនៃបណ្ដឹងវិវាទមួយផ្សេងទៀត។

## II. សំណើនេះមិនអាចទទួលយកបាន[2]

2. សំណើនេះមិនអាចទទួលយកបានដោយសារមូលហេតុមួយចំនួន។ ទីមួយ វាមុនពេលវេលា មធ្យោបាយគតិយុត្តិទាំងអស់សម្រាប់បំពេញកិច្ចស្របតាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក *មិន* ទាន់ប្រើប្រាស់អស់នៅឡើយ។ ទីពីរ សហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) លែងទទួលសំណុំរឿង ០០៤ ទៀតហើយ និងមិនមានសិទ្ធិអំណាចក្នុងការបំពេញកិច្ចទេ។ ពួកគាត់ *ពុំមានសិទ្ធិអំណាចផ្លូវការបន្ថែម* ភ្លាមៗបន្ទាប់ពីការចេញដីកាដំណោះស្រាយ លើកលែងតែមុខងាររដ្ឋបាលដែលមានចែងយ៉ាងច្បាស់នៅក្នុងក្របខណ្ឌ អ.វ.ត.ក ដែលមិនអនុវត្តចំពោះសំណើរនេះទេ។ ជាងនេះទៀត ស.ច.ស មិនមានយុត្តាធិការដែលមានជាប់មកជាមួយណាមួយ ដែលនឹងដណ្ដើមយកសិទ្ធិសំណាចរបស់អង្គជំនុំជម្រះផ្សេងទៀត ដែលកំពុងប្ដឹងអំពីសំណុំរឿង ០០៤ ទេ។ ក្នុងករណីណាក៏ដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមែនជាវេទិការត្រឹមត្រូវ សម្រាប់សំណើដែលស្នើសុំឱ្យ ស.ច.ស មោឃភាពដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះទេ។ តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតមិនមានសិទ្ធិអំណាច ក្នុងការមោឃភាពដីកាដំណោះស្រាយ

---

[1] ឯកសារ **D386** សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យ បញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារជាបន្ទាន់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ (“សំណើសុំឱ្យបញ្ចប់”)។

[2] ស.ព.អ កត់សម្គាល់ផងដែរថា សំណើរបស់ យឹម ទិត្យ មិនអាចទទួលយកបាន ពីព្រោះវាគឺជាការដាក់ឯកសារមិនគ្រប់គ្រាន់។ ឯកសារ ២១ ទំព័រ លើសចំនួនកំណត់ ១៥ ទំព័រ ដែលអនុញ្ញាតដោយមាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/វិសោធនកម្មទី៨ ត្រូវបានកែប្រែនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២។ ស.ព.អ កត់សម្គាល់ទៀតថា អំណះអំណាងមួយចំនួនទាក់ទងនឹងភាពអាចទទួលយកបាន ក៏បង្ហាញថាសំណើនោះខ្វះអង្គសេចក្ដីផងដែរ។

របស់ខ្លួននោះទេ។ ជាចុងក្រោយ ស.ច.ស មិនមានគុណវុឌ្ឍិក្នុងការពិចារណាលើអង្គសេចក្តីនៃសំណើនេះទេ ផ្អែកលើអគតិជាក់ស្តែងរបស់ខ្លួន និងការបង្ហាញឲ្យឃើញនូវអគតិ ដោយសារពួកគាត់បានធ្វើការកំណត់ទុកជាមុនលើបញ្ហានេះ។

## ក. រាល់មធ្យោបាយគតិយុត្តិទាំងអស់សម្រាប់ការអនុវត្តស្របតាមក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក *មិន*ត្រូវបានប្រើប្រាស់អស់លទ្ធភាពនៅឡើយ

3. សំណើនេះមិនទាន់ដល់ពេល និងផ្អែកលើការអះអាងមិនត្រឹមត្រូវដែលថា លទ្ធភាពគតិយុត្តិទាំងអស់សម្រាប់បញ្ជូនរឿងក្តីទៅជំនុំជម្រះត្រូវបានប្រើប្រាស់អស់[3]។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ត្រូវបានជូនដំណឹងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១[4] ហើយនៅចំពេលនៃសំណើនេះ យឹម ទិត្យ បានដឹងថា ស.ព.អ មានបំណងប្តឹងសាទុក្ខទៅ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក")[5]។ បណ្តឹងសាទុក្ខនេះត្រូវបានដាក់នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១[6] ហើយ អ.ជ.ត.ក មិនទាន់ចេញសេចក្តីសម្រេចរបស់ខ្លួននៅឡើយទេ។

4. ផ្ទុយទៅនឹងការអះអាងមិនត្រឹមត្រូវរបស់ យឹម ទិត្យ[7] ពាក់ព័ន្ធនឹងបញ្ហាច្បាប់ ស.ច.ស មិនអាចបញ្ចប់រឿងក្តី នៅពេលដែលមានបណ្តឹងវិវាទកំពុងបន្តនៅក្នុងវេទិការមួយផ្សេងទៀត គឺ អ.ជ.ត.ក។ ស.ច.ស ក៏បានទទួលស្គាល់ផងដែរថា នេះគឺជាគោលការណ៍ច្បាប់ដែលត្រូវបានបង្កើត

---

[3] ឯកសារ **D386** សំណើសុំឲ្យបញ្ចប់ KH 01679708 (សេចក្តីផ្តើម) កថាខណ្ឌ ៤៦។

[4] ឯកសារ **D381/45 & D382/43** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ("សេចក្តីពិចារណា")។ សំណុំរឿង ០០៤ សារអេឡិចត្រូនិកពីសេចក្តីជូនដំណឹងរបស់មន្ត្រីទទួលបន្ទុកសំណុំរឿង អំពីឯកសារ **D381/45 & D382/43** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ម៉ោង ៥:០៥ ល្ងាច។ *សូមមើលផងដែរ* សំណុំរឿង ០០២-**F43** សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលានិងចំនួនទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ កថាខណ្ឌ ១២។

[5] ឯកសារ **D386** សំណើសុំឲ្យបញ្ចប់ កថាខណ្ឌ ២-៤។

[6] *សូមមើល* សំណុំរឿង ០០៤/២៣-០៩-២០២១-អ.វ.ត.ក/អ.ជ.ត.ក(០៦)-2 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចដែលបានតម្រូវ ដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ("បណ្តឹងសាទុក្ខរបស់ ស.ព.អ") EN 01679603។ វាត្រូវបានជូនដំណឹងទៅកាន់ភាគីនៅថ្ងៃបន្ទាប់។។ *សូមមើល* សំណុំរឿង ០០៤/២៣-០៩-២០២១-អ.វ.ត.ក/អ.ជ.ត.ក(០៦) សារអេឡិចត្រូវនិកពីសេចក្តីជូនដំណឹងរបស់មន្ត្រីទទួលបន្ទុកសំណុំរឿង អំពីបណ្តឹងសាទុក្ខរបស់ ស.ព.អ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ម៉ោង ១១:៤៦ ព្រឹក។

[7] ឯកសារ **D386** សំណើសុំឲ្យបញ្ចប់ កថាខណ្ឌ ១០, ៤១, ៤៥។

ឡើងយ៉ាងត្រឹមត្រូវ[8]។ តាមពិត ស.ច.ស បានបញ្ជាក់យ៉ាងស៊ីចង្វាក់គ្នាថា ខ្លួននឹងមិនធ្វើអន្តរាគមន៍ទេ ក្នុងករណីដែលមានមធ្យោបាយផ្លូវច្បាប់ផ្សេង "ជម្រុញដល់សំណុំរឿងនេះ ឲ្យទៅជំនុំជម្រះ ឬ ទៅដល់ការបិទបញ្ចប់"[9]។ នៅក្នុងសំណុំរឿង ០០៤/២ ស.ច.ស មិនធ្វើការសម្រេចលើសំណើរបស់ អោ អាន សុំឲ្យបោះត្រា និងបញ្ចូលរឿងក្តីក្នុងបណ្ណសារ នៅពេលដែល ស.ព.អ ក្រោយមកបានប្តឹងសាទុក្ខទៅ អ.ជ.ត.ក[10]។ នៅក្នុងសំណុំរឿង ០០៣ ស.ច.ស បានស្នើសុំឲ្យ ស.ព.អ បញ្ជាក់ពីបំណងរបស់គាត់ក្នុងការប្តឹងសាទុក្ខទៅ អ.ជ.ត.ក និងបានណែនាំភាគីថា ប្រសិនបើមិនមានបណ្តឹងទៅ អ.ជ.ត.ក ទេនោះ ពួកគេនឹងដាក់សារណាជាលាយលក្ខណ៍អក្សរស្តីពីយុត្តាធិការរបស់ ស.ច.ស ក្នុងការបញ្ចប់រឿងក្តី[11]។ ការទាយស្មានរបស់ យឹម ទិត្យ លើវិធីដែល អ.ជ.ត.ក នឹងដោះស្រាយជាមួយសំណុំរឿង ០០៤[12] គឺមិនពាក់ព័ន្ធទៅនឹងអង្គហេតុដែលថា លទ្ធភាពគតិយុត្តិផ្សេងទៀតនៅតែកំពុងតែត្រូវបានស្វែងរក។

## ខ. ស.ច.ស មិនត្រូវបានប្តឹងអំពីសំណុំរឿង ០០៤ ទេ

---

[8] *សូមមើល* សំណុំរឿង ០០៣-**D270/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ("សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី") កថាខណ្ឌ ៤០។

[9] សំណុំរឿង ០០៣-**D270/7** សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី កថាខណ្ឌ ៤២ ("ប្រសិនបើមិនមានមធ្យោបាយណាផ្សេងដើម្បីជម្រុញដល់សំណុំរឿងនេះ ឲ្យទៅជំនុំជម្រះ ឬទៅដល់ការបិទបញ្ចប់ [...] ហើយប្រសិនបើ *មិនមាន*ស្ថាប័នតុលាការដទៃណា នៅក្នុងតុលាការនេះ មានចេតនាក្នុងការទទួលយកមកអនុវត្តដោយខ្លួនឯង *នូវមធ្យោបាយណាមួយនោះ ជាចម្រើសចុងក្រោយបំផុត* និង*បន្ទាប់ពី*ដំណើរការអស់នូវយុត្តាធិការទាំងឡាយដែលមាន ពួកយើងនឹងបើកឱកាស [...] ថាតើពួកយើងមានយុត្តាធិការដែលនៅសេសសល់ពិសេសណាមួយ *ដែលជាមធ្យោបាយចុងក្រោយបំផុត* ក្នុងការបិទបញ្ចប់សំណុំរឿងដោយខ្លួនឯង" (គូសបញ្ជាក់បន្ថែម))។ *សូមមើលផងដែរ* កថាខណ្ឌ ៤០។

[10] សំណុំរឿង ០០៤/២-**D364** អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេត មានចំណងជើងថា "សំណើរបស់មាធាវីការពារក្តីចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ - ឯកសារ D363 ("សំណើរ") ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

[11] សំណុំរឿង ០០៣-**D273** ដីកាបង្គាប់ឲ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ("ដីកាបង្គាប់ឲ្យដាក់សេចក្តីសន្និដ្ឋានបញ្ចប់សំណុំរឿង") ផ្នែកសម្រេចសេចក្តី។ *សូមមើលផងដែរ* កថាខណ្ឌ ៥, ៧។

[12] ឯកសារ **D386** សំណើសុំឲ្យបញ្ចប់ កថាខណ្ឌ ១៣ (លើកឡើងថា អ.ជ.ត.ក នឹងមិនចេញសេចក្តីសម្រេចណាមួយដែលនឹងនាំឲ្យរឿងក្តីបន្តដំណើរការទៅជំនុំជម្រះឡើយ) កថាខណ្ឌ ១៨ (ស្នើឡើងដោយតុល្យភាពថា ព្រោះ ស.ច.ស ត្រូវបោះត្រា និងដាក់សំណុំរឿងនេះក្នុងបណ្ណសារ បន្ទាប់ពី អ.ជ.ត.ក មិនបានធ្វើក្នុងសំណុំរឿង ០០៤/២ ករណីដូចគ្នានឹងកើតឡើងក្នុងសំណុំរឿង ០០៤)។

5. យឹម ទិត្យ ក៏មើលរំលងផងដែរ[13]នូវអង្គហេតុដែលថា គឺ អ.ប.ជ មិនមែន ស.ច.ស ទេ ដែល "មានយុត្តាធិការចុងក្រោយនៅក្នុងដំណាក់កាលមុនការជំនុំជម្រះ"[14]។ ស.ច.ស "លែងមានសិទ្ធិអំណាចផ្លូវការបន្ថែមទៀតហើយ (*functus officio*) បន្ទាប់ពីបានចុះហត្ថលេខាលើផ្នែកសេចក្ដីសម្រេចនៃដីកាដំណោះស្រាយរួច"[15] និងមានបណ្ដឹងឧទ្ធរណ៍ជាច្រើនបានដាក់ប្រឆាំងនឹងដីកា

---

[13] ឯកសារ **D386** សំណើសុំឱ្យបញ្ចប់ កថាខណ្ឌ ៤៧ ("ស.ច.ស មានយុត្តាធិការផ្ដាច់មុខ និងសិទ្ធិអំណាចក្នុងការបិទបញ្ចប់សំណុំរឿង ០០៤") កថាខណ្ឌ ៤០ ("ស.ច.ស ត្រូវអនុវត្តយុត្តាធិការសេសសល់របស់ខ្លួន"), KH 01679711 ("ផ្នែកទី ១៖ យុត្តាធិការផ្ដាច់មុខរបស់ ស.ច.ស លើសំណុំរឿង ០០៤")។ *សូមមើលផងដែរ* កថាខណ្ឌ ៨-៩។

[14] សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្ដីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្ដី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ("សេចក្ដីសម្រេចរួមរបស់ អ.ប.ជ") កថាខណ្ឌ ៦៩ (*ដកស្រង់ ក្នុងចំណោមរឿងផ្សេងទៀត* សំណុំរឿង ០០១-**D99/3/42** សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បញ្ជូនខ្លួន កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៤១។ សំណុំរឿង ០០៤/២-**D359/24 & D360/33** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្ដីពិចារណាសំណុំរឿង ០០៤/២") កថាខណ្ឌ ៤១។ សំណុំរឿង ០០៤/២-**D360/3** សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្ដោះអាសន្ន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៥, ១៣។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D266/27 & D267/35** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ("សេចក្ដីពិចារណា សំណុំរឿង ០០៣") យោបល់របស់ចៅក្រម Olivier Beauvallet និង Kang Jin Baik ("យោបល់របស់ចៅក្រមអន្តរជាតិ") កថាខណ្ឌ ១៣២-១៣៣ ("មាត្រា ១២(២) នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង "ការិយាល័យតុលាការចុងក្រោយដែលទទួលបានសំណុំរឿងត្រូវធ្វើការពិនិត្យឡើងវិញចំពោះឯកសារស្ដីពីសុវត្ថិភាពនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញនៅក្នុងសំណុំរឿង [...] គឺអង្គបុរេជំនុំជម្រះ ឬ អង្គជំនុំជម្រះតុលាការកំពូល")។

[15] សំណុំរឿង ០០៤/១-**D308/3/1/20** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ ជើងទំព័រ ១៨៦ *ដកស្រង់ ក្នុងចំណោមរឿងផ្សេងទៀត* សំណុំរឿងលេខ ០០៣-**D266/27 & D267/35** សេចក្ដពិចារណាក្នុងសំណុំរឿង ០០៣ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៣២។ អំណះអំណាងរបស់ ស.ច.ស ថា ពួកគាត់មិនអាចលែងមានសិទ្ធិអំណាចផ្លូវការបន្ថែមទៀតនោះទេ ពីព្រោះតែនៅក្នុងសំណុំរឿង ០០៤/២ ចៅក្រមអង្គបុរេជំនុំជម្រះបានចេញសេចក្ដីណែនាំទៅកាន់អង្គភាពបណ្ណសារ ពីរបៀបដំណើរការរឿងក្ដី មើលរំលងថា សេចក្ដីណែនាំទាំងនោះបានកើតឡើងនៅក្នុងខែមករា *មុនពេល*ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានបង្កើតឡើងត្រឹមត្រូវ ដោយការដាក់ឱ្យដំណើរការឡើងវិញនៃ ស.ច.ស.អ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។ *សូមមើល* សំណុំរឿង ០០៣-**D270/7** សេចក្ដីសម្រេចលើការបញ្ជូនរឿងក្ដី កថាខណ្ឌ ៣៨។ សំណុំរឿង ០០៤/២-**D359/36 & D360/45** អនុស្សរណៈអន្តរការិយាល័យពីចៅក្រម Olivier Beauvallet និង Kang Jin Baik មានចំណងជើងថា "ការបញ្ជូនសំណុំរឿង ០០៤/២" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ២៧-២៨, ៣១។ សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សហចៅក្រម*

ដំណោះស្រាយក្នុងសំណុំរឿង ០០៤។ ដូច្នេះ ស.ច.ស អាចតាមបែបរដ្ឋបាល "ចាត់ការសំណុំរឿង ដោយអនុលោមតាមវិធាន ៧៧(១៣) និង ៧៧(១៤) នៃវិធានផ្ទៃក្នុង"[16] តែប៉ុណ្ណោះ និងមិនមាន សិទ្ធិអំណាចក្នុងការចេញសេចក្តីសម្រេច និងដីកាជាសារធាតុ ដែលទាក់ទងនឹងដំណាក់កាល មុនការជំនុំជម្រះនោះទេ[17]។ ការបដិសេធមិនប្រកាន់ខ្ជាប់ទៅនឹងអាណត្តិគតិយុត្តិរបស់ អ.វ.ត.ក ក្នុងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង រួមគ្នា ឬជាឯកត្តោភាគី ទៅកាន់ អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ")[18] មិនមានន័យថាជាការឯកភាពតាមផ្លូវច្បាប់ក្នុង ការបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់រឿងក្តីនោះទេ។

## គ. ស.ច.ស មិនមានយុត្តាធិការដែលមានជាប់មកជាមួយនោះទេ

6. ស.ច.ស មិនមានយុត្តាធិការដែលមានជាប់មកជាមួយក្នុងការស្តាប់សំណើនេះ អនុលោមតាមវិធាន ២១ ឬវិធានផ្សេងទៀត ដូចដែល យឹម ទិត្យ បានអះអាងនោះទេ[19]។ ដូចដែលបានបង្ហាញខាងលើ[20] ស.ច.ច *មិន* ត្រូវបានប្តឹងអំពីសំណុំរឿង ០០៤ ទេ ហើយមិនអាចដណ្តើមយកអំណាចរបស់

---

*ស៊ើបអង្កេតអន្តរជាតិត្រូវបានតែងតាំងឡើងវិញ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២។

[16] សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដូចដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") ឬ ("វិធាន")។ *សូមមើលផងដែរ* សំណុំរឿង០០៣-**D266/27 & D267/35** សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ទំព័រ ៥៦ (ផ្នែកសម្រេចសេចក្តី)។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា ទំព័រ ៦៩-៧០ (ផ្នែកសម្រេចសេចក្តី)។

[17] សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៦៩។

[18] *សូមមើល* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៥(៤), ៧(៤)។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ ថ្មី។ វិធាន ១(២)។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៦៧ ("ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតមួយរូបអាចបំពេញកិច្ចតែម្នាក់ឯងដោយត្រឹមត្រូវ") រួមទាំងជើងទំព័រលេខ ១៨១។

[19] ឯកសារ **D386** សំណើសុំឱ្យបញ្ចប់ កថាខណ្ឌ ៩-១២។ *សូមមើលផងដែរ* កថាខណ្ឌ ៧, ៣៤, ៣៨, ៤០ (យោងទៅ "យុត្តិធិការសេសសល់" ដែលទាយស្ពានរបស់ ស.ច.ស) កថាខណ្ឌ ៤៧ និង KH 01679711 (យោងទៅ "យុត្តាធិការផ្តាច់មុខ" ដែលទាយស្ពានរបស់ ស.ច.ស)។

[20] *សូមមើល* កថាខណ្ឌ ៣-៥ *យោងខាងលើ* ។

អង្គជំនុំជម្រះផ្សេងទៀតនៃ អ.វ.ត.ក ដែលមានសិទ្ធិលើរឿងក្ដីយ៉ាងត្រឹមត្រូវនោះបានឡើយ។ ហេតុដូច្នេះ ការសំអាងរបស់ យឹម ទិត្យ លើការសន្និដ្ឋានរបស់ អ.ជ.ត.ក ថា យុត្តាធិការដែលមានជាប់មកជាមួយ កើតមាននៅពេលដែលបញ្ហានានាបង្ហាញថា មានលក្ខណៈ "ចៃដន្យ" ទៅនឹងនីតិវិធីដែលអង្គជំនុំជម្រះមួយត្រូវបានប្ដឹងរួចហើយនោះ គឺជាការយល់ខុស ព្រោះ ស.ច.ស មិនមានយុត្តាធិការចំបងបែបនោះទេ[21]។ មិនពាក់ព័ន្ធស្រដៀងគ្នានេះដែរគឺ សេចក្ដីថ្លែងរបស់ ស.ច.ស ក្នុងឆ្នាំ ២០១៧ ថា ខ្លួនមានអំណាចដែលមានជាប់មកជាមួយក្នុងការបញ្ចប់រឿងក្ដី "នៅពេលដែល 'ស្ថានភាព និងចក្ខុវិស័យទៅមុខទៀត [...] មិនស្របតាមគោលការណ៍គ្រឹះនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌'"[22]។ ទោះបីជាមានកំហុសនៅក្នុងកាលៈទេសៈណាមួយ ក្នុងឆ្នាំ២០១៧ ការស៊ើបអង្កេតនៅតែបន្ត និងខុសពីពេលនេះ កាលនោះ ស.ច.ស នៅតែប្ដឹងអំពីសំណុំរឿង ០០៤។ ក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនៃ អ.វ.ត.ក ទាំងអស់បានបញ្ជាក់យ៉ាងច្បាស់ថា ភាពទទួលយកបានអនុលោមតាមវិធាន២១ គឺមានលក្ខណៈពិសេស និងអាចត្រូវបានប្រើតែនៅពេលដែលអង្គហេតុ និងកាលៈទេសៈជាក់លាក់នានាតម្រូវឱ្យធ្វើដូច្នេះប៉ុណ្ណោះ[23]។ ដោយហេតុថា បញ្ហាជំនុំជម្រះ

---

[21] *សូមមើល* ឯកសារ **D386** សំណើសុំឱ្យបញ្ចប់ កថាខណ្ឌ១០ *ដកស្រង់* សំណុំរឿង ០០២-**E284/2/1/2** សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ កថាខណ្ឌ ១២ (កត់សម្គាល់លេខឯកសារមិនត្រឹមត្រូវដែលបានដកស្រង់ដោយ យឹម ទិត្យ) និងសំណុំរឿង ០០២-**E463/1/3** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្ដីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ កថាខណ្ឌ ១៧។

[22] ឯកសារ **D386** សំណើសុំឱ្យបញ្ចប់ កថាខណ្ឌ ១១, ៤៥ (ដកស្រង់ត្រង់កថាខណ្ឌ ១១) *ដកស្រង់* ឯកសារ **D355/9** ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្ដី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ១៦ (ដកស្រង់ក្នុងឯកសារ **D355** សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ១)។ ដូចបានបង្ហាញនៅក្នុងកថាខណ្ឌ ២៤ *យោងខាងក្រោម* ស.ព.អ សន្និដ្ឋានថា លទ្ធភាពរបស់អង្គជំនុំជម្រះក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី លើកលែងអង្គសេចក្ដីនៃរឿងក្ដី គឺមានកម្រិតខ្លាំង និងថា លក្ខខណ្ឌតម្រូវខ្ពស់មិនត្រូវបានបំពេញលើអង្គហេតុនៃសំណុំរឿង ០០៤។

[23] *សូមមើលឧទាហរណ៍* អ.ជ.ត.ក៖ សំណុំរឿង០០២-**E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ១៤-១៥។ អ.ប.ជ៖ សំណុំរឿង០០២-**A410/2/6** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើរស្ដីពីការរក្សាការសម្ងាត់ សមភាព និងភាពយុត្តិធម៌ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ១០។ ក.ស.ច.ស៖ ឯកសារ **D185/1** ដីកាសម្រេចស្ដីពីញត្តិរបស់ តា អាន ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៧៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤

ដោយត្រឹមត្រូវយុត្តិធម៌ណាមួយ ដែល យឹម ទិត្យ អាចចង់លើកឡើង ត្រូវបានស្តាប់ដោយអង្គជំនុំជម្រះ ដែលបច្ចុប្បន្នត្រូវបានប្តឹងអំពីសំណុំរឿង ០០៤ មិនមានមូលហេតុពិសេស ដែលចាំបាច់តម្រូវឲ្យមានអន្តរាគមន៍របស់ ស.ច.ស នោះទេ។

## ឃ. ស.ច.ស ពុំមានសិទ្ធិអំណាចផ្លូវច្បាប់ដើម្បីច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ

7. សំណើក៏មិនអាចទទួលយកបានផងដែរដោយសារ ស.ច.ស ពុំមានយុត្តាធិការសម្រេចលើសំណើសុំជាក់លាក់ណាមួយឡើយ ទោះក្នុងករណីណាក៏ដោយ[24]។ យឹម ទិត្យ សន្មតថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺត្រូវបានទុកជាមោឃៈហើយ[25]។ តាមពិតគឺមិនដូច្នេះទេ។ ដូចករណីសំណុំរឿង ០០៤ ដែលបច្ចុប្បន្នកំពុងតែនៅជាធរមានដែរ មានន័យថា បន្ទាប់ពីសេចក្តីពិចារណារបស់ អ.ប.ជ ដែលមិនបានសម្រេចបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលុប[26] និងមុន

---

("សេចក្តីសម្រេចស្តីពីមោឃភាពក្នុងរឿងក្តី អោ អាន") កថាខណ្ឌ ២៩ ("ការអនុវត្តវិធានផ្ទៃក្នុង ២១ ដើម្បីជាមធ្យោបាយទទួលបានញត្តិផ្សេងៗ/សំណើដែលមិនអាចទទួលយកតាមវិធានផ្ទៃក្នុងផ្សេងទៀត គឺត្រូវបានចាត់ទុកថាការអនុវត្តក្នុងករណីពិសេស ហើយអាចប្រើប្រាស់បានតែក្នុងករណីដែលអង្គហេតុ និងកាលៈទេសៈតម្រូវឲ្យប្រើប្រាស់បែបនោះប៉ុណ្ណោះ") ជើងទំព័រ ៣៧ ("ទោះបីជាការប្រើប្រាស់វិធានផ្ទៃក្នុង ២១ ជាមធ្យោបាយនីតិវិធីមួយដើម្បីស្នើសុំសំណើប្រភេទផ្សេងៗត្រូវបានពិភាក្សានៅក្នុងរង្វង់កិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ [ស.ច.ស] យល់ឃើញថា ការដាក់កម្រិតដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល អាចអនុវត្តបានយ៉ាងសមស្របលើញត្តិ ដែលបានដាក់នៅតុលាការថ្នាក់ដំបូង")។

[24] អង្គជំនុំជម្រះ អ.វ.ត.ក បានទទួលស្គាល់ថា សំណើទាំងឡាយដែលបានធ្វើទៅចំពោះមុខចៅក្រមដែលមិនមានយុត្តាធិការលើសំណើទាំងនោះ គឺមិនអាចទទួលយកបានទេ។ *សូមមើលឧទាហរណ៍* សំណុំរឿង ០០២-ឯកសារ **C22/I/41** សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃសេចក្តីសង្កេតជាទូទៅរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ ៥ ("អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការពិចារណាលើការជំទាស់ចំពោះវិសោធនកម្មលើសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ទេ ហេតុដូច្នេះសេចក្តីសង្កេត មិនអាចទទួលយកបានឡើយ")។ ឯកសារ **D185/1** សេចក្តីសម្រេចស្តីពីមោឃភាពក្នុងរឿងក្តី អោ អាន កថាខណ្ឌ ៣៣ ("ឧបាស្រ័យដែលបានស្នើដោយមេធាវីការពារក្តីមិនអាចទទួលយកបានទាំងពីរ [...] និងមិនអាចរកបានអនុលោមតាមវិធាន ៧៦ ដោយហេតុថា អំណាចក្នុងការធ្វើមោឃភាពលើកិច្ចស៊ើបសួរ មិនស្ថិតនៅលើ ស.ច.ស ទេ ប៉ុន្តែស្ថិតនៅលើ អ.ប.ជ")។ សំណុំរឿង ០០៣-ឯកសារ **C2/4** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ មតិយោបល់របស់ចៅក្រម Olivier Beauvallet និង Steven J. Bwana កថាខណ្ឌ ១៧ ("សំណើសុំផ្អាក [...] មិនស្ថិតក្នុងយុត្តាធិការ។ វា [...] មិនអាចទទួលយកបានឡើយ")។

[25] *សូមមើលឧទាហរណ៍* ឯកសារ **D386** សំណើសុំបញ្ចប់ ទំព័រ ១ ("[ដីកាដំណោះស្រាយ] *ត្រូវបានទុក* ជាមោឃៈ (បញ្ជាក់សេចក្តីបន្ថែម")) កថាខណ្ឌ ១៣ ("ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ *ត្រូវបានទុក* ជាមោឃៈ និងគ្មានអនុភាពផ្លូវច្បាប់ មានន័យថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤ គ្មានសុពលភាព") (បញ្ជាក់សេចក្តីបន្ថែម")) កថាខណ្ឌ ១៤, ១៦។

[26] *សូមមើល* ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា។

ពេល អ.ជ.ត.ក ធ្វើការសម្រេចលើបណ្តឹងសាទុក្ខនៅចំពោះមុខខ្លួន ដីកាបញ្ជូនរឿងទៅជំនុំជម្រះ *នៅតែមានសុពលភាព*។ សំណើនេះព្យាយាមធ្វើយ៉ាងណាឲ្យ ស.ច.ស ប្រើប្រាស់នូវសេចក្តីសម្រេចមួយរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿងមួយ (សំណុំរឿង ០០៤/២) *ធ្វើឲ្យ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅជាមោឃៈនៅក្នុងសំណុំរឿងមួយផ្សេងទៀត(សំណុំរឿង ០០៤)[27]។ សំណើនេះមិនត្រឹមតែបរាជ័យឈរលើអង្គសេចក្តីនេះប៉ុណ្ណោះទេ[28] ប៉ុន្តែដើម្បីផ្តល់អនុភាពទៅលើសំណើសុំនេះ គឺតម្រូវឲ្យ ស.ច.ស មានសិទ្ធិអំណាចក្នុងការធ្វើមោឃភាពទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព។ ពុំមានអំណាចដូច្នេះមានអត្ថិភាពនោះទេ។ ក្រៅអំពីការពិតដែលថា ស.ច.ស *ពុំមានសិទ្ធិអំណាចផ្លូវការបន្ថែម* ស្របតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក៏គ្មានបទប្បញ្ញត្តិណាអនុញ្ញាតឲ្យ ស.ច.ស ធ្វើមោឃៈភាពចំពោះដីកាដំណោះស្រាយរបស់ខ្លួនឯងដែរ[29]។

### ង. ការកំណត់ជាមុនរបស់ ស.ច.ស អំពីថាតើសំណុំរឿងនេះគួរបន្តទៅជំនុំជម្រះដែលឬអត់ក៏ធ្វើឲ្យពួកគេគ្មានគុណវុឌ្ឍិដែរ

8. យឹម ទិត្យ ធ្វើសំណើរបស់ខ្លួនទៅ ស.ច.ស ដោយមានចេតនា ដោយសារពួកគេបានកំណត់ជាមុនរួចហើយអំពីលទ្ធផលនៃសំណុំរឿងនេះ[30]។ ក្នុងសំណុំរឿង ០០៣ ស.ច.ស បានប្រកាសជាចំហនៅក្នុង

[27] *សូមមើល* សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ (“សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ”)។ *ផ្ទុយពី* ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ១៣, ១៧, ៤៨។ សំណុំរឿង ០០៣-ឯកសារ **D270/7** សេចក្តីសម្រេចស្តីពីការបញ្ជូនសំណុំរឿង កថាខណ្ឌ ៣៦។

[28] *សូមមើល* ផ្នែក III.ខ.២. *យោខាងក្រោម*។ ដូចបានពន្យល់បន្ថែមខាងក្រោម សេចក្តីសម្រេចរបស់ អ.ជ.ត.ក ចេញពីរឿងក្តីមួយរបស់ អ.វ.ត.ក មិនអាចបន្តសាបព្រោះទៅលើសេចក្តីសម្រេចផ្សេងទៀតទេ ជាពិសេសករណីដែលមានសំអាងហេតុសមផលដូចជាករណីនេះជាដើម ដែលត្រូវងាកចេញពីសេចក្តីសម្រេចក្នុងសំណុំរឿង ០០៤/២ របស់ អ.ជ.ត.ក ដែលបានសម្រេចថា ដីកាដំណោះស្រាយពីរបានចេញដោយខុសច្បាប់ គឺត្រូវបានចាត់ទុកជាមោឃៈ និងអសុពលភាព។

[29] អំណាចក្នុងការធ្វើមោឃភាពដីកាដំណោះស្រាយនៅដំណាក់កាលមុនការជំនុំជម្រះ គឺស្ថិតនៅលើ អ.ប.ជ ក្រោយបណ្តឹងសាទុក្ខក្រោមវិធាន ៦៧(៥), ៧៣, ៧៤ និង ៧៧។ (ដីកាដំណោះស្រាយមិនអាចកែប្រែនីតិវិធីនៃវិធាន ៧៦ បានឡើយ)។ *សូមមើល* វិធាន ៧៦(២) និង (៤)។ សំណុំរឿង ០០៣-ឯកសារ **D158/1** សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាពដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៧-១៨)។

[30] *សូមមើល ឧទាហរណ៍* ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ៧, ១២, ២៩, ៣៤-៣៥, ៣៨។

សេចក្ដីសម្រេចចំនួនពីរថា ការបញ្ចប់សំណុំរឿងនេះគឺជាជម្រើសតែមួយគត់ដែលពួកគេនឹងពិចារណា[31] ។ ពួកគេក៏បានឲ្យដឹងក្នុងដីកាសម្រេចតាមផ្លូវតុលាការមួយផងដែរថា ពាក្យសុំណាមួយដែល ស.ព.អ អាចនឹងធ្វើទៅ អ.ជ.ត.ក គឺមានតែពាក្យសុំឲ្យបញ្ចប់ប៉ុណ្ណោះ[32]។

9. យ៉ាងណាមិញ ការប្រើតេស្ដ៍សាកល្បងផ្លូវច្បាប់សម្រាប់អគតិ ដែលត្រូវបានប្រើប្រាស់ជាប្រចាំនៅ អ.វ.ត.ក និងដោយមានការយកចិត្តទុកដាក់អំពីសច្ចធារណ៍នៃនិរទោស និងលក្ខខណ្ឌភ័ស្ដុតាងកម្រិតខ្ពស់[33] ស.ច.ស ពុំមានគុណវុឌ្ឍិក្នុងការពិចារណាលើអង្គសេចក្ដីនៃសំណើសុំនេះទេ ដោយផ្អែកលើអគតិជាក់ស្ដែងរបស់ពួកគេ និងការលេចឡើងនៃអគតិ។ ទោះបីជាមានការកំណត់ជាមុនរបស់ ស.ច.ស ត្រូវបានធ្វើឡើងនៅក្នុងសំណុំរឿង ០០៣ ក៏ដោយ ករណីទាំងពីរ ពាក់ព័ន្ធនឹងការខកខានក្នុងការបញ្ជូនសំណុំរឿងទៅជំនុំជម្រះដូចបានតម្រូវតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដូចគ្នា រួមទាំងដោយឈរ

---

[31] *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D270/7** សេចក្ដីសម្រេចស្ដីពីការបញ្ជូនសំណុំរឿង កថាខណ្ឌ ១៩, ៣៦-៣៧, ៤២។ សំណុំរឿង ០០៣-ឯកសារ **D273** ដីកាបង្គាប់ឲ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីការបញ្ចប់ កថាខណ្ឌ ៥-៦។ *សូមមើលផងដែរ* សំណុំរឿង ០០៣-ឯកសារ **D271/5 & D272/3** សេចក្ដីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧៤(២) ("ស.ច.ស 'បានសម្រេចរួចហើយលើវាសនានៃសំណុំរឿងនេះ' ក្នុងករណីដែលវាបានវិលត្រឡប់មករកខ្លួន")។

[32] សំណុំរឿង ០០៣-ឯកសារ **D273** ដីកាបង្គាប់ឲ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីការបញ្ចប់ កថាខណ្ឌ ៧។

[33] រឿងក្ដី *Furundžija,* IT-95-17/1-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ១៨៩ ("វិធានទូទៅដែលចៅក្រមមិនត្រឹមតែមិនលម្អៀងជាអត្តនោម័តិប៉ុណ្ណោះទេ ប៉ុន្តែចៅក្រមក៏មិនត្រូវស្ថិតក្រោមកាលៈទេសៈអ្វីៗទាំងអស់ដែលនាំឲ្យកើតមាន ឬលេចឡើងនូវអគតិជាសត្យានុម័ត")។ [...] ខាងក្រោមនេះ គួរតែជាសេចក្ដីណែនាំក្នុងការបកស្រាយ និងអនុវត្តដោយមិនលម្អៀងនូវលក្ខខណ្ឌតម្រូវនៃច្បាប់លក្ខន្តិកៈ ក) ចៅក្រមមិនលម្អៀង ប្រសិនបើត្រូវបានបង្ហាញថា អគតិជាក់ស្ដែងបានកើតឡើង។ ខ) មានការលេចឡើងនៃអគតិដែលមិនអាចទទួលយកបាន ប្រសិនបើ [...] កាលៈទេសៈនានានឹងនាំឲ្យអ្នកសង្កេតការណ៍សមហេតុផលនិងដែលបានជ្រួតជ្រាបម្នាក់ នឹងយល់បានដោយសមហេតុផលអំពីអគតិ"); ១៩០ ("អ្នកសង្កេតការណ៍សមហេតុផល" គឺជាបុគ្គលដែលបានជ្រួតជ្រាប មានចំណេះដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិដែលបង្កើតបានជាផ្នែកមួយនៃសារតា ហើយបានផ្ដល់ដំណឹងផងដែរអំពីការពិតដែលថា អនាគតិគឺជាករណីកិច្ចមួយរបស់ចៅក្រមដែលបានស្បថលើកតម្កល់យ៉ាងខ្ពស់")។ សំណុំរឿង ០០២-ឯកសារ **C11/29** សេចក្ដីសម្រេចជាសាធារណៈស្ដីពីបណ្ដឹងជំទាស់ចិត្តជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ធុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ កថាខណ្ឌ ១៩-២១។ សំណុំរឿង ០០២/៣១-១០-២០១៩-អ.វ.ត.ក/អ.ជ.ត.ក(០៣)-11 សេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្តរបស់ ខៀវ សំផន ចំពោះចៅក្រមអង្គជំនុំជម្រះសាលាឧទ្ធរណ៍ប្រាំមួយរូប ដែលកាត់សេចក្ដីនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ កថាខណ្ឌ ៦៣-៦៤។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សាលដីកាសំណុំរឿង០០២/០១") កថាខណ្ឌ ១១២។

លើមូលដ្ឋានគោលជំហរស្វ័យប្រវត្តិផង[34] ហើយ ស.ច.ស បានបញ្ជាក់ច្បាស់ថា មុខតំណែងរបស់ពួកគេអនុវត្តស្មើភាពគ្នាចំពោះរាល់រឿងក្តីដែលនៅសេសសល់ទាំងអស់ រួមទាំងសំណុំរឿង ០០៤ ផងដែរ[35]។ តាមពិត យឹម ទិត្យ កត់សម្គាល់ថា "ការយល់ព្រមបញ្ចប់រឿងក្តី" ក្នុងសំណុំរឿង ០០៣ ធ្វើឲ្យទៅជា"កត្តាកំណត់សម្រាប់ ស.ច.ស" ក្នុងការធ្វើដូចគ្នានឹងសំណុំរឿង ០០៤[36]។

## III. បើទោះបីជា ស.ច.ស មានសិទ្ធិអំណាចក្តី ក៏សំណើនេះមិនមានអង្គសេចក្តីដែរ

### ១. គោលការណ៍ស្មើភាពគ្នា មិនអាចធ្វើជាយុត្តិកម្ម ដល់ការបញ្ចប់សំណុំរឿង ០០៤ ឡើយ

---

[34] *សូមមើល* វាក្យខណ្ឌ III.ខ.៣ *យោងខាងក្រោម*។ *សូមមើលផងដែរ* ផ្នែកសម្រេចសេចក្តី នៅក្នុងសំណុំរឿង ០០៣-ឯកសារ **D266/27 & D267/35** សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ទំព័រ ៥៦ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី, ទំព័រ ៥៨-៥៩ មតិយោបល់របស់ចៅក្រមអន្តរជាតិ ទំព័រ ២០៧។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា ទំព័រ ៦៩-៧០ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី, ទំព័រ ៧៨ យោបល់របស់ចៅក្រម Judges Kang Jin Baik និង Olivier Beauvallet ("មតិយោបល់របស់ចៅក្រមអន្តរជាតិ") ទំព័រ ៣៥០។ *សូមមើលផងដែរ* សំណុំរឿង ០០៣-ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២, ៧៦។

[35] *សូមមើល* ឯកសារ **D270/7** សេចក្តីសម្រេចលើការបញ្ជូនរឿងក្តី កថាខណ្ឌ ១៩ ("ប្រសិនបើពួកយើងបានទទួលការជូនដំណឹងបែបនេះអំពីមតិរួមគ្នារបស់អង្គបុរេជំនុំជម្រះ [ស្តីពីភាពស្របច្បាប់នៃដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា] ក្នុងលក្ខណៈលឿនជាងនេះនោះ សំណុំរឿងដែលនៅសល់ទាំងអស់អាចនឹងត្រូវបានដោះស្រាយ ឲ្យបានឆាប់បំផុតដូចដែលអាចធ្វើទៅបាន តាមរយៈសេចក្តីសម្រេចរួម ដែលអាចត្រឹមតែជា*ការបញ្ចប់ភ្លាមៗនូវសំណុំរឿងទាំងអស់ដែលនៅសេសសល់* បន្ទាប់ពីការលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/១ (គូសបញ្ជាក់បន្ថែម)")។ មិនមានអ្នកសង្កេតការណ៍សមហេតុផលណាអាចជឿថា ស.ច.ស នឹងអនុម័តគោលជំហរផ្សេងបន្ទាប់ពីនេះទេ។ *សូមមើល ឧទាហរណ៍* រឿងក្តី *Rudnichenko ទល់នឹងប្រទេស អ៊ុយក្រែន* លេខ 2775/07, សាលក្រម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ១១៦ (ចៅក្រមមួយរូប "បានពិនិត្យពីដំបូងលើអង្គសេចក្តីនៃរឿងក្តីរបស់សហចុងចោទរបស់ម្ចាស់ពាក្យសុំ ខ នៅក្នុងក្របខ័ណ្ឌដែលគាត់បានបញ្ចេញទស្សនាអំពីការចូលរួមពាក់ព័ន្ធ និងតួនាទីរបស់ពួកគេទាំងពីរនាក់ គឺខ និងចុងចោទ [...]។ រឿងក្តីទាំងពីរដូចបានពោលខាងលើ គឺមានការពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ដូចគ្នា និងមានបង្កប់ន័យលើការវាយតម្លៃលើភ័ស្តុតាងដូចគ្នា") ១១៨។ រឿងក្តី *Buscemi ទល់នឹងប្រទេស អ៊ីតាលី* លេខ 29569/95, សាលក្រម ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៨ (ចៅក្រមមួយរូប "បានប្រើប្រាស់ពាក្យពេចន៍នានាដែលមានបង្កប់ន័យថា គាត់បានបង្កើតទស្សនមិនអនុគ្រោះមួយចំពោះករណីរបស់ម្ចាស់ពាក្យសុំ នៅមុនពេលគាត់ឡើងធ្វើជាអធិបតីក្នុងសវនាការដែលត្រូវធ្វើការសម្រេចលើរឿងនោះ") ៦៩។ រឿងក្តី *Olujić ទល់នឹងប្រទេស ក្រូអាត* លេខ 22330/05, សាលក្រម ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ៥៩, ៦៥, ៦៨។ រឿងក្តី *Lavents ទល់នឹង Latvia*, លេខ 58442/00, សាលក្រម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១១៩ (បុរេទស្សនៈដែលបានបង្កើតជាមុនថា ការរួចទោសពេញលេញមិនអាចធ្វើទៅរួចនោះ គឺជាគោលជំហរពិតប្រាកដមួយលើរឿងក្តីដែលមិនទាន់បានធ្វើការសម្រេច និងជាការពេញចិត្តច្បាស់លាស់មួយក្នុងការស្វែងរកពិរុទ្ធភាព) ១២១។

[36] ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ២៩, ៤០។

10. យឹម ទិត្យ បានស្នើសុំឲ្យបញ្ចប់សំណុំរឿងរបស់គាត់ ដោយផ្អែកដោយផ្នែក លើមូលដ្ឋានសិទ្ធិទទួលបានការប្រព្រឹត្តដោយស្មើភាពគ្នារបស់គាត់ ជាមួយ អោ អាន[37]។ ប៉ុន្តែទឡ្ហីករណ៍របស់គាត់មិនមានអង្គសេចក្តីឡើយ ព្រោះគាត់មិនបានទទួលស្គាល់អំពីភាពមិនអាចអនុវត្តបានលើគោលការណ៍នេះ នៅពេលដែលការប្រព្រឹត្តចំពោះអ្នកដទៃ គឺផ្អែកលើកំហុសអង្គច្បាប់។

11. ទស្សនៈនៃការប្រព្រឹត្តដោយស្មើភាពគ្នា ត្រូវបានបង្កើតឡើងជាធាតុផ្សំគន្លឹះ នៃការការពារសិទ្ធិមនុស្ស និងដើម្បីធានានូវនីតិរដ្ឋ[38]។ គោលការណ៍នេះធានាថា ភាគីនានានៃកិច្ចដំណើរការនីតិវិធី រដ្ឋប្បវេណី និង/ឬ ព្រហ្មទណ្ឌ គឺទទួលបាននូវភាពស្មើគ្នា ទាំងអង្គសេចក្តីនិងនីតិវិធី[39]។ នៅ អ.វ.ត.ក មូលដ្ឋាននៃគោលការណ៍នេះគឺមានចែងនៅក្នុង វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង៖

---

[37] ឯកសារ **D386** សំណើសុំបិទបញ្ចប់សំណុំរឿង កថាខណ្ឌ ១៣, ១៧, ៤២-៤៥។

[38] គណកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងអង្គជំនុំជម្រះ CCPR/C/GC/32 ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ("មតិយោបល់ទូទៅលេខ ៣២") កថាខណ្ឌ ២-៤, ៧។

[39] <u>ជាអង្គសេចក្តី</u> ភាពស្មើគ្នាការពារបុគ្គល ពីការរើសអើង ដោយផ្អែកលើការកំណត់ប្រភេទ ដែលបានការពារតាមផ្លូវច្បាប់។ សូមមើលមតិយោបល់ទូទៅលេខ ៣២ កថាខណ្ឌ ៨ -៩។ ការកំណត់ប្រភេទទាំងអស់នេះរួមមាន សិទ្ធិហាមឃាត់ពីការរើសអើងតាមអំពើចិត្ត ដោយផ្អែកលើ ក្នុងចំណោមរឿងផ្សេងទៀត ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាល ជាតិឬប្រភពដើមសង្គម ដើមកំណើត និងឋានៈដទៃទៀត។ *សូមមើលផងដែរ* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អនុម័តថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ១៩៩៣ និងវិសោធនកម្មថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ មាត្រា ៣១ ("ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពនិងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត")។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ មហាសន្និបាត UN Doc. A/Res/3/217A, មាត្រា ៧។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ 999 UNTS 171 ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៤(១)។ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានធ្វើបច្ចុប្បន្នភាព សម្រាប់អតីតប្រទេសយូហ្គោស្លាវី ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ មាត្រា ២១(១)។ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ្វាន់ដារ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ វិសោធនកម្មថ្ងៃទី៣១ ខែមករា ឆ្នាំ២០១០ មាត្រា ២០(១)។ លក្ខន្តិកៈតុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន ភ្ជាប់ជាឧបសម្ពន្ធទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសេរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេសសម្រាប់សេរ៉ាឡេអូន ទីក្រុង Freetown ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ 2178 UNTS 137 មាត្រា ១៧(១)។ លក្ខន្តិកៈតុលាការពិសេស សម្រាប់ប្រទេសលីបង់ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៧ ក្រុមប្រឹក្សាសន្តិសុខ UN Doc. S/Res/1757 (ឯកសារភ្ជាប់) មាត្រា ១៦(១)។ <u>ជាកិច្ចដំណើរការនីតិវិធី</u> គោលការណ៍នេះធានានូវការទទួលបាន សិទ្ធិកិច្ចដំណើរការនីតិវិធីដូចគ្នានិងធានាផងដែរនូវសិទ្ធិទទួលបានស្មើភាពគ្នា និងសមភាពនៃគូរភាគី។ សូមមើលមតិយោបល់ទូទៅលេខ ៣២, កថាខណ្ឌ ៨-៩, ១២-១៤។ *សូមមើលផងដែរ* S. Negri, "គោលការណ៍សមភាពនៃគូភាគី និងការវិវឌ្ឍន៍នៃច្បាប់ នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ" International Criminal Law Review 5 លេខ ៤ (ឆ្នាំ២០០៥) ទំព័រ ៥២៣, ៥៤៤-៥៤៥, ៥៧១។

"បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និង ត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត"[40] ប៉ុន្តែការប្រព្រឹត្តដោយស្មើភាពគ្នាធានា "មិនធ្វើឱ្យមានភាពខុសគ្នាទាំងស្រុង នៃការប្រព្រឹត្ត ដោយការរើសអើងឡើយ"[41]។

12. ជាមូលដ្ឋាន ការអនុវត្តគោលការណ៍ការប្រព្រឹត្តដោយស្មើភាពគ្នា មិនអនុញ្ញាតឱ្យ ស.ច.ស អាចធ្វើមោឃភាពដីកាដំណោះស្រាយរបស់ពួកគេ ឬបញ្ចប់សំណុំរឿងរបស់ យឹម ទិត្យ ឡើយ។ ក្រៅពីការដែល ស.ច.ស មិនមានសិទ្ធិអំណាចក្នុងការសម្រេចដូច្នេះហើយ[42] សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២[43] គឺផ្អែកលើកំហុសឆ្គងអង្គច្បាប់ ដែលកើតចេញពីសេចក្តីសម្រេចដោយខុសឆ្គងរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា គឺជារឿងខុសច្បាប់[44]។

13. យឹម ទិត្យ *មិន*បានផ្តល់ឯកសារណាមួយ ដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ស.ច.ស ចាំបាច់ត្រូវគោរពតាម សេចក្តីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ ឡើយ។ ការពឹងផ្អែករបស់គាត់ទៅលើ ការសម្រេចរបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្សដែលថា "សច្ចភាពគតិយុត្តិ [...] តម្រូវផងដែរ ក្នុងចំណោមរឿងផ្សេងទៀត ថា ក្នុងករណីដែលតុលាការ បានសម្រេចជាស្ថាពរទៅលើបញ្ហាមួយហើយ ការសម្រេចនោះមិនអាចត្រូវបានចោទសួរ" គឺជាការ

---

[40] វិធាន ២១(១)(ខ) នៃវិធានផ្ទៃក្នុង។

[41] *S.W.M Broeks តទល់នឹង ប្រទេសហូឡង់* បណ្តឹងលេខ 172/1984, UN Doc. Supp. No. 40 (A/42/40) ថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៨៧ នៅត្រង់ទំព័រ ១៣៩ កថាខណ្ឌ ១៣ (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* មតិយោបល់ទូទៅលេខ ៣២ កថាខណ្ឌ ១៣-១៤ (ការដាកចេញអាចផ្តល់យុត្តិកម្មផងដែរផ្អែកលើ "មូលដ្ឋានសត្យានុម័ត និងសមហេតុផល")។

[42] សូមមើល កថាខណ្ឌ ៥-៧ *យោងខាងលើ*។

[43] សំណុំរឿង ០០៤/២ ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល លើបណ្តឹងសាទុក្ខភ្លាមៗ។

[44] បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ១៨-២០, ៣៦-៤៤។ *សូមមើលបន្ថែម* ផ្នែក III.ខ *យោងខាងក្រោម* បង្ហាញថា ដីកាដំណោះស្រាយមិនត្រូវបានចេញដោយខុសច្បាប់ឡើយ ហើយបើទោះជាសម្រាប់ការពិភាក្សា ការចេញដីកាដំណោះស្រាយក្នុងពេលជាមួយគ្នា មិនត្រូវបានអនុញ្ញាតតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក្តី ក៏ការពិតនេះមិនបានធ្វើឱ្យ ដីកាដំណោះស្រាយទាំងពីរ មោឃៈ និងអសុពលភាពឡើយ ហើយក៏មិនអនុញ្ញាតឱ្យមាន ការបិទបញ្ចប់សំណុំរឿង ០០៤ ដោយមិនមានការបង្ហាញអំពីភាពអយុត្តិធម៌ធ្ងន់ធ្ងរ ឬព្យសនកម្មជាក់ស្តែង និងក្នុងករណីតម្លៃនៃប្រយោជន៍យុត្តិធម៌ នៃការមិនបន្តកិច្ចដំណើរការនីតិវិធី ទៅជំនុំជម្រះ មានទម្ងន់ធ្ងន់ជាង ព្យសនកម្មដែលបានទាយស្មានណាមួយ។

លើកឡើងដោយខុសឆ្គង[45]។ យុត្តិសាស្ត្រដែលបានដកស្រង់ ពាក់ព័ន្ធបញ្ហានៃអាជ្ញាអស់ជំនុំ ក្នុងរឿងក្តីជាក់លាក់មួយ[46] *គឺមិនមែន*ជាការប្រព្រឹត្តដោយស្មើភាពគ្នា រវាងភាគីផ្សេងគ្នា ចំពោះរឿងក្តីផ្សេងគ្នាឡើយ។ តាមពិតទៅតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានបញ្ជាក់ច្បាស់ថា "លក្ខខណ្ឌតម្រូវនៃសច្ចភាពគតិយុត្តិ និងការការពារទំនុកចិត្តស្របច្បាប់ចំពោះសាធារណជន មិនអាចសម្របសម្រួលជាមួយ សិទ្ធិដែលបានតម្រូវ សម្រាប់ភាពស៊ីចង្វាក់គ្នានៃយុត្តិសាស្ត្រឡើយ"[47]។ ហើយតុលាការនេះក៏មិនបានគាំទ្រការអះអាងដែលថា ការប្រព្រឹត្តដោយស្មើភាពគ្នាតម្រូវ ឬគាំទ្រកំហុសអង្គច្បាប់ដែលកើតឡើងរហូតឡើយ។

---

[45] ឯកសារ **D386** សំណើសុំបិទបញ្ចប់សំណុំរឿង កថាខណ្ឌ ១៧ ជើងទំព័រ ៣៨ (ដកស្រង់រឿងក្តី *Brumărescu តទល់នឹង ប្រទេសរូម៉ានី* សំណុំរឿងលេខ ២៨៣៤២/៩៥សាលក្រម (អង្គសេចក្តី) ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ ("រឿងក្តី *Brumărescu*") កថាខណ្ឌ ៦១, រឿងក្តី *Kehaya និងអ្នកដទៃទៀត តទល់នឹងប្រទេសប៊ុលហ្គារី* សំណុំរឿងលេខ ៤៧៧៩៧/៩៩ និង ៦៨៦៩៨/០១ សាលក្រម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ ("រឿងក្តី *Kehaya និងគូកន*") កថាខណ្ឌ ៦១, រឿងក្តី *Ryabykh ទល់នឹងប្រទេសរុស្ស៊ី* សំណុំរឿងលេខ ៥២៨៥៤/៩៩ សាលក្រម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៣ ("រឿងក្តី *Ryabykh*") កថាខណ្ឌ ៥១)។

[46] រឿងក្តី *Brumărescu* កថាខណ្ឌ ១៤-២៥, ៥៦-៦៥ (បន្ទាប់ពីដីកាស្ថាពរត្រូវបានអនុវត្ត អគ្គរដ្ឋអាជ្ញា បានស្នើសុំឱ្យបដិសេធ ហើយតុលាការកំពូលយុត្តិធម៌បានសម្រេចតាម។ តុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្សបានថ្លែងថា ការនេះរំលោភបំពានទៅលើអាជ្ញាអស់ជំនុំ ដោយសារតែសេចក្តីសម្រេចរបស់តុលាការ ត្រូវបានអនុវត្ត។ រឿងក្តី *Kehaya និងអ្នកដទៃទៀត* កថាខណ្ឌ ១២-២៦, ៧១-៧៧ (តុលាការកំពូលបានតម្កល់ការប្រគល់ដីទៅឱ្យអ្នកដាក់ពាក្យសុំវិញ។ អាជ្ញាធរព្រៃឈើរដ្ឋ បានដាក់សំណើសុំឱ្យប្រកាសថា កម្មសិទ្ធិរបស់អ្នកដាក់ពាក្យសុំគឺខុសច្បាប់ ដែលនាំឱ្យតុលាការកំពូលចេញដីកាសម្រេច ឱ្យអ្នកដាក់ពាក្យសុំបោះបង់ចោលដី។ តុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បាននិយាយថា តុលាការកំពូល បានដកហូតនូវអានុភាពផ្លូវច្បាប់ នៃសាលក្រមពីមុន ដែលត្រូវបានអនុវត្ត។ ជាលទ្ធផល រដ្ឋបានរំលោភទៅលើគោលការណ៍ សច្ចភាពគតិយុត្តិ និងមិនមានផលប្រយោជន៍សាធារណៈ ដើម្បីជាយុត្តិកម្ម ដល់ការពិនិត្យឡើងវិញនូវជម្លោះ ក្នុងការដកហូតទ្រព្យសម្បត្តិ ដោយមិនមានសំណង។ រឿងក្តី *Ryabykh*, កថាខណ្ឌ ៧-៣០, ៥១-៥៨ (នៅពេលដែលរដ្ឋដាក់សំណើសុំ ពិនិត្យឡើងវិញលើការផ្តល់ជាស្ថាពរ បន្ទាប់ពីចាប់ផ្តើមកិច្ចដំណើរការនីតិវិធីអនុវត្តសាលក្រម មានការបង្វិលរឿងក្តីទៅតុលាការចំនួនបួនដង។ តុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានកត់សម្គាល់ក្នុងរឿងក្តីនេះ ថាបានដំណើរការនីតិវិធីឆ្លងកាត់ ដំណើរការតុលាការពេញលេញ ដូច្នេះមិនគួរមានការពិនិត្យថ្មីឡើយ។ រដ្ឋបាលរំលោភទៅលើគោលការណ៍ សច្ចភាពគតិយុត្តិ ដោយសារតែរដ្ឋបានជ្រៀតជ្រែកទៅលើគោលការណ៍ស្ថាពរនៃសាលដីកា)។

[47] រឿងក្តី *Stanković និង Trajković តទល់នឹង ប្រទេសស៊ែប៊ី* សំណុំរឿងលេខ ៣៧១៩៤/០៨ និង ៣៧២៦០/០៨ សាលក្រម ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៤០(៦) (បញ្ជាក់ថា "ការវិវឌ្ឍន៍ករណីយុត្តិសាស្ត្រផ្ទាល់មិនផ្ទុយទៅនឹងរដ្ឋបាលតុលាការត្រឹមត្រូវនោះទេ ដោយហេតុថា ការបរាជ័យក្នុងរក្សាវិធីសាស្ត្រដ៏ស្វាហាប់ និងប្រែប្រួល នឹងមានហានិភ័យដល់ការរារាំងកំណែទម្រង់ ឬការធ្វើឱ្យប្រសើឡើង"។ សូមមើលផងដែរ រឿងក្តី *Unédic តទល់នឹង ប្រទេសបារាំង* សំណុំរឿងលេខ ២០១៥៣/០៤ សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៤ (ការបកប្រែក្រៅផ្លូវការ៖ ប៉ុន្តែតុលាការពិចារណាថា

14. នៅក្នុងលក្ខណៈដូចគ្នា ទាំងនៅ អ.វ.ត.ក និងនៅតុលាការ និងសាលាក្តីអន្តរជាតិដទៃទៀត[48] *មិនមាន*កាតព្វកិច្ចដាច់ខាត ក្នុងការរក្សាទុកសំអាងហេតុ និងសេចក្តីសន្និដ្ឋាន នៃរឿងក្តីកន្លងមកឡើយ។ សិទ្ធិស្មើភាពគ្នាមិនមែនជាសិទ្ធដាច់ខាតឡើយ ហើយក៏មិនមែនជាឧបសគ្គរាំង សម្រាប់តុលាការឡើយ។ ទោះបីថាជារឿងសមស្របផ្នែកច្បាប់ ដែលតុលាការត្រូវគោរពតាម សេចក្តីសម្រេចកន្លងមករបស់ខ្លួន ក្នុងការស្វែងរកសច្ចភាពគតិយុត្តិក្តី នេះគឺគ្រាន់តែជាសច្ចធារណ៍ដែលថា សេចក្តីសម្រេចទាំងអស់នោះ មានភាពត្រឹមត្រូវប៉ុណ្ណោះ[49]។ អ.ប.ជ បានបញ្ជាក់ត្រឹមត្រូវថា

---

លក្ខខណ្ឌតម្រូវនៃសច្ចភាពគតិយុត្តិ និងការការពារការរំពឹងទុកដោយស្របច្បាប់របស់ម្ចាស់បណ្តឹង មិនបានបង្កើតជាសិទ្ធិដែលទទួលបាន ក្នុងយុត្តិសាស្ត្រដែលមានសង្គតភាពឡើយ")។ រឿងក្តី *Atanasovski តទល់នឹងអតីតសាធារណរដ្ឋយូហ្គោស្លាវីម៉ាសេដូនី* សំណុំរឿងលេខ ៣៦៨១៥/០៣ សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ កថាខណ្ឌ ៣៨។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការយោងរបស់ យឹម ទិត្យ ទៅរករឿងក្តី *Ştefănică និងអ្នកដទៃទៀត តទល់នឹងប្រទេសរូម៉ានី* សំណុំរឿងលេខ ៣៨១៥៥/០២ សាលក្រម ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ ("រឿងក្តី *Ştefănică*") កថាខណ្ឌ ៣៧-៣៨ (*សូមមើល*ឯកសារ **D386** សំណើសុំបញ្ចប់សំណុំរឿង ជើងទំព័រ ៣៨) មិនបានផ្លាស់ប្តូរការសន្និដ្ឋាននេះឡើយ។ ផ្ទុយគ្នានឹងការអះអាងរបស់ យឹម ទិត្យ (*សូមមើល*ឯកសារ **D386** សំណើសុំបញ្ចប់សំណុំរឿង កថាខណ្ឌ ១៧, ៤២) រឿងក្តី *Ştefănică* មិនមែនជាឯកសារ សម្រាប់ការអះអាងថា តុលាការចាំបាច់ត្រូវគោរពតាម សេចក្តីសម្រេចដែលខុសឆ្គងកន្លងមកទេ។ ប៉ុន្តែតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានសម្រេចថា មានការរំលោភទៅលើមាត្រា ៦ ដោយផ្អែកលើការអនុវត្តច្បាប់តាមអំពើចិត្ត ដែលនាំទៅដល់ "ការជំនុំជម្រះដែលមិនស៊ីចង្វាក់គ្នា ចំពោះបណ្តឹងដែលលើកឡើង ដោយមនុស្សជាច្រើននាក់នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា ដែលនាំទៅដល់ស្ថានភាពមិនប្រាកដប្រជា"។ តុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ការពារប្រជាជនពីងាកចេញតាមអំពើចិត្ត និងដូចៗគ្នា ក្នុងការអនុវត្តច្បាប់ គឺមិនមែនការវិវឌ្ឍច្បាប់ដែលបានពិចារណា ដែលរួមមានការកែតម្រូវ ទៅលើយុត្តិសាស្ត្រដែលខុសឆ្គងឡើយ។

[48] *សូមមើលជាឧទាហរណ៍* លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៤៦ 33 UNTS 993 មាត្រា ៣៨(១)(ឃ), ៥៩។ លក្ខន្តិកទីក្រុងរ៉ូម តុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ("លក្ខន្តិកទីក្រុងរ៉ូម") 2187 UNTS 90 មាត្រា ២១(២)។ សូមមើលបន្ថែម *South West Africa* ដំណាក់កាលទីពីរ សាលក្រម ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៦៦ របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៦៦ មតិដាច់ដោយឡែករបស់ចៅក្រម Van Wyk ទំព័រ ៦៧។ *Barcelona Traction, Light and Power Company, Limited,* អញ្ញត្រកម្ម, សាលក្រម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៦៤ របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៦៤ មតិដាច់ដោយឡែក ចៅក្រម Tanaka ទំព័រ ៦៥។ ពាក់ព័ន្ធតុលាការ ICTY តុលាការ ICTR និងតុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *សូមមើល* ជើងទំព័រ ៥១ *យោងខាងក្រោម*។

[49] ដូចបានចែងនៅ កថាខណ្ឌ ២៦ នៃមតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាតែអំពីសមភាព និងយុត្តិធម៌លើនីតិវិធី ហើយមិនអាចបកស្រាយថាធានា ពីការមិនមានកំហុសឆ្គង លើផ្នែកនៃអង្គជំនុំជម្រះមានសមត្ថកិច្ចឡើយ។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ (សូមមើលជាឧទាហរណ៍ សំណុំរឿង ០០៤/១ ឯកសារ **D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ("ដីកាដំណោះស្រាយរបស់ អ៊ឹម

"គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ មិនអាចត្រូវបានបកស្រាយ ដើម្បីកំណត់ថា ការភ័ន្តច្រឡំនៅក្នុងរឿងក្តីមួយ នឹងត្រូវអនុវត្តតាម នៅក្នុងរឿងក្តីមួយទៀត នាពេលអនាគតទេ ទោះបីជាការភ័ន្តច្រឡំនោះ ផ្តល់ជាប្រយោជន៍ ចំពោះជនត្រូវចោទក៏ដោយ"[50]។ បើទោះបីក្នុងករណីដែលសំណុំរឿងពីរ មានលក្ខណៈប្រហាក់ប្រហែលគ្នាក្តី ប្រសិនបើមាន "សំអាងហេតុសមស្រប" ក្នុងការងាកចេញពីសេចក្តីសម្រេចកន្លងមក តុលាការត្រូវតែអនុវត្តដូច្នេះ ដើម្បីជាប្រយោជន៍យុត្តិធម៌[51]។

---

ថែម សំអាងហេតុ) កថាខណ្ឌ ១០។ សំណុំរឿង ០០៣ ឯកសារ **D87/2/1.7/1** ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនិងជម្លោះប្រដាប់អាវុធ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៣) ដែលថា អ.វ.ត.ក ដំណើរការក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលគោលការណ៍នៃទ្រឹស្តី ប្រកាន់យកតាមសេចក្តីសម្រេចពីមុន មិនអាចអនុវត្តបានឡើយ។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេត បានបដិសេធកន្លងមក មិនគោរពតាមសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះ ជាអង្គជំនុំជម្រះទទួលបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលបុរេជំនុំជម្រះ (សូមមើលជាឧទាហរណ៍ សំណុំរឿង ០០៤/២ ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៣៥-៣៨)។

[50] សំណុំរឿង ០០២-ឯកសារ **D390/1/2/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយក ការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្តាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៥។

[51] *សូមមើលជាឧទាហរណ៍* រឿងក្តី *Aleksovski* សំណុំរឿងលេខ IT-95-14/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ១០៧-១០៨ ("ដើម្បីប្រយោជន៍នៃសច្ចភាព និងភាពអាចប៉ាន់ប្រមាណបាន អង្គជំនុំជម្រះតុលាការកំពូល គួរតែគោរពតាមសេចក្តីសម្រេចកន្លងមករបស់ខ្លួន ប៉ុន្តែអង្គជំនុំជម្រះមានសេរីភាពក្នុងការងាកចេញ ពីសេចក្តីសម្រេចកន្លងមក បើមានសំអាងហេតុសមស្រប ដើម្បីជាប្រយោជន៍យុត្តិធម៌។ ឧទាហរណ៍នៃស្ថានភាពដែល សំអាងហេតុសមស្របដើម្បីប្រយោជន៍យុត្តិធម៌ តម្រូវឲ្យមានការងាកចេញ ពីសេចក្តីសម្រេចកន្លងមក មានដូចជាករណីដែលសេចក្តីសម្រេចកន្លងមក ត្រូវបានសម្រេចដោយផ្អែកលើមូលដ្ឋាន នៃគោលការណ៍គតិយុត្តិឬរឿងក្តីមិនត្រឹមត្រូវ ដែលសេចក្តីសម្រេចកន្លងមកត្រូវបានធ្វើឡើង ផ្អែកលើសេចក្តីសម្រេចដែលមានស្រាប់")។ រឿងក្តី *Semanza* សំណុំរឿងលេខ ICTR-97-23-A ដីកាសម្រេចអង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ កថាខណ្ឌ ៩២។ រឿងក្តី *Galić* សំណុំរឿងលេខ IT-98-29-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ១១៧។ រឿងក្តី *Kordić & Čerkez* សំណុំរឿងលេខ IT-95-14/2-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១០៤០។ រឿងក្តី *Šainović និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-05-87-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ១៦៥០ ("ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូល [...] បានបដិសេធយ៉ាងច្បាស់លាស់ នូវវិធីសាស្ត្រដែលបានអនុម័ត ក្នុងសាលដីកាឿងក្តី *Perišić* ដោយសារតែវាប្រឆាំងដោយផ្ទាល់និងជាក់ស្តែង ជាមួយយុត្តិសាស្ត្រដែល

15. សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បានកត់សម្គាល់ផងដែរ អំពីគោលជំហរមិនស្របគ្នា និងបែបឱកាសនិយមរបស់ យឹម ទិត្យ ទៅលើភាពអនុវត្តបាននៃគោលការណ៍ស្មើភាពគ្នា។ នៅពេលស្នើសុំឱ្យ ស.ច.ស *ងាកចេញពី* យុត្តិសាស្ត្ររបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០១ លើយុត្តាធិការបុគ្គល យឹម ទិត្យ បានស្នើសុំជាពិសេសដល់ ស.ច.ស ឱ្យប្រព្រឹត្តផ្សេងគ្នាពី ឌុច[52]។ គាត់បានលើកទឡ្ហីករណ៍ថា អ.វ.ត.ក មិនស្ថិតជាកម្មវត្ថុនៃទ្រឹស្តី ប្រកាន់យកតាមសេចក្តីសម្រេចពីមុន (*stare decisis*) ហើយថាមិនមានសំអាងហេតុជាគោលការណ៍ ក្នុងការអនុម័តយកជំហរនៃការគោរពតាមផ្លូវតុលាការជាក់ស្តែង ចំពោះ អ.ជ.ត.ក ឡើយ ក្នុងករណីដែលមាន "សំអាងហេតុសមស្រប" សម្រាប់អង្គជំនុំជម្រះក្នុងការបញ្ចេញទស្សនៈផ្ទាល់របស់ខ្លួន[53]។ ដោយផ្ទុយគ្នាទាំងស្រុងទៅនឹងគោលជំហររបស់គាត់នាពេលនេះ យឹម ទិត្យ បានព្យាយាមបញ្ចុះបញ្ចូល ស.ច.ស នៅពេលនោះថា ការគោរពតាមទស្សនៈរបស់ អ.ជ.ត.ក នឹងរំលោភបំពានទៅលើគោលការណ៍សច្ចភាពគតិយុត្តិ[54]។

---

នៅជាធរមាន ស្តីពីធាតុផ្សំសត្យានុម័តនៃការទទួលខុសត្រូវលើការជួយ និងជម្រុញ និងជាមួយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងករណីនេះ"។ រឿងក្តី Cossey *តទល់នឹងចក្រភពអង់គ្លេស* សំណុំរឿងលេខ ១០៨៤៣/៨៤ សាលក្រម ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ១៩៩០ កថាខណ្ឌ ៣៥ (តុលាការបានកត់សម្គាល់ថា ទោះបីជាមិនជាប់កាតព្វកិច្ចខ្លាំងក្លាក្តី តែជាធម្មតាតុលាការត្រូវគោរពតាមសេចក្តីសម្រេចកន្លងមករបស់ខ្លួន ហើយអាចងាកចេញពីសេចក្តីសម្រេចទាំងនោះតែក្នុងករណី "មានសំអាងហេតុសមស្រប" ក្នុងការងាកចេញទេ)។ ចំពោះការអនុវត្តកន្លងមក របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សូមមើលសំណុំរឿង ០០៤/១ ឯកសារ **D308/3** ដីកាដំណោះស្រាយ អ៊ឹម ចែម សំអាងហេតុ កថាខណ្ឌ ១០ (សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា ដើម្បីរក្សា "ភាពច្បាស់លាស់ និងភាពដូចគ្នានៃច្បាប់" ពួកគេនឹងគោរពតាមយុត្តិសាស្ត្ររបស់ អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែនឹងងាកចេញពីយុត្តិសាស្ត្រនោះ ក្នុងករណីមាន "សំអាងហេតុពិសេស")។ សំណុំរឿង ០០៣ ឯកសារ **D181** ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ២៨ ("ដើម្បីជាប្រយោជន៍សច្ចភាពផ្លូវច្បាប់ និងសមភាពនៅចំពោះមុខច្បាប់ សហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តគោលការណ៍ច្បាប់ និងវិធានឱ្យស្របតាមការយល់ឃើញរបស់ អ.ជ.ត.ក ប្រសិនបើមិនមានមូលហេតុផ្ទុយសមស្រប")។

[52] ឯកសារ **D378/5** ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ") កថាខណ្ឌ ២២៣ ("មតិរបស់អង្គជំនុំជម្រះតុលាការកំពូលត្រូវបានបង្ហាញឡើងក្នុងកាលៈទេសៈនៃសំណុំរឿង ០០១ ហើយមិនបានកំណត់ជាយុត្តិសាស្ត្រដែលសហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវតែគោរពតាមនៅក្នុងសំណុំរឿង ០០៤ ឡើយ")។

[53] ឯកសារ **D378/5** ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ ចំណងជើង I.ក.ii(ក) កថាខណ្ឌ ១៨៣ ជើងទំព័រ ២៤០ *ដកស្រង់* សំណុំរឿង ០០១-ឯកសារ **E188** សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ជើងទំព័រ ៩៧៩។

[54] ឯកសារ **D378/5** ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពរ ចំណងជើង I.ក.ii(ខ)(6)។

16. *ការមិនគោរពតាម*សេចក្តីសម្រេចកន្លងមក ដោយសារកង្វះការប្រុងប្រយ័ត្ន (*per incuriam*) គឺធានានូវភាពអាចប៉ាន់ប្រមាណ តម្លាភាព និងភាពស្របគ្នានៅក្នុងការអនុវត្តច្បាប់។ ការគោរពចំពោះសេចក្តីសម្រេចកន្លងមក ដោយផ្អែកតែទៅលើភាពប្រហាក់ប្រហែលគ្នានៃទំនាស់ចំនួនពីរ ធ្វើឲ្យទន់ខ្សោយដល់លក្ខណៈត្រឹមត្រូវ និងអំណាចនៃច្បាប់។ វាជាការគោរពដែលមិនមានភាពចាំបាច់នេះ មិនមែនការអនុវត្តដោយស្វ័យប្រវត្តិ នូវច្បាប់ដែលខុសឆ្គងទេ ដែល "កាត់បន្ថយសេចក្តីទុកចិត្តរបស់ សាធារណជនជាតិនិងអន្តរជាតិ ចំពោះប្រព័ន្ធតុលាការ អ.វ.ត.ក"[55]។ ភាពស៊ីចង្វាក់គ្នានិងសច្ចភាពគតិយុត្តិ នៅក្នុងការធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការ មិនអាចតម្រូវឲ្យប្រព្រឹត្តកំហុសឆ្គងដដែលឡើងវិញឡើយ គឺកំហុសឆ្គងដែលថា ក្នុងករណីនេះ ធ្វើឲ្យអាប់ឱនដល់ភាពស្របច្បាប់ និងទំនុកចិត្តរបស់អ.វ.ត.ក[56]។

## ខ. មានសំអាងហេតុច្បាស់លាស់និងសមស្រប ក្នុងការងាកចេញពីសេចក្តីសម្រេច របស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២

17. សេចក្តីសម្រេចរបស់ អ.ជ.ត.ក នៅក្នុងសំណុំរឿង ០០៤/២ មិនគួរត្រូវបានអនុវត្តតាមឡើយ នៅក្នុងសំណុំរឿង ០០៤ ដោយសារតែសេចក្តីសម្រេចនេះ ផ្អែកលើការសម្រេចដោយខុសឆ្គងរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរក្នុងពេលតែមួយ គឺជារឿងខុសច្បាប់ ដែលបណ្តាលឲ្យ អ.ជ.ត.ក សន្និដ្ឋានដោយខុសឆ្គងថា ការចេញបែបនេះធ្វើឲ្យដីកាដំណោះស្រាយនីមួយៗ មោឃៈនិងអសុពលភាព[57]។ មានសំអាងហេតុសមស្របជាច្រើន ក្នុងការងាកចេញពីការសម្រេចរបស់ អ.ជ.ត.កៈ (១) ផ្ទុយពីគោលជំហររបស់ អ.ប.ជ ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា មិនមែនជារឿងខុសច្បាប់ទេ (២) បើទោះបីជាខុសច្បាប់ក្តី ការចេញបែបនេះមិនបានធ្វើឲ្យដីកាដំណោះស្រាយទៅជាមោឃៈ និងអសុពលភាពឡើយ ហើយវាក៏មិនធានាឲ្យមានការបញ្ចប់រឿងក្តីនេះដែរ និង (៣) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយសំឡេង

---

[55] ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ៤៤។

[56] សូមមើល បណ្តឹងសាទុក្ខរបស់ ស.ព.អ *ទាំងស្រុង*។

[57] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥១ (វំឭកពីការសម្រេចសេចក្តីជាឯកច្ឆន្ទរបស់ អ.ប.ជ), ៥៣, ៦១, ៦៧-៦៩, ៧១។

ភាគច្រើនលើសលប់របស់ អ.ប.ជ ឡើយ ដូច្នេះសំណុំរឿង ០០៤ គួរត្រូវបានបញ្ជូនទៅជំនុំជម្រះ។ នាពេលនេះ បញ្ហាទាំងអស់នេះកំពុងស្ថិតនៅចំពោះមុខ អ.ជ.ត.ក ក្នុងបណ្តឹងសាទុក្ខ[58]។

*(១) ដីកាដំណោះស្រាយផ្ទុយគ្នា ក្នុងសំណុំរឿង ០០៤ មិនត្រូវបានចេញដោយខុសច្បាប់ទេ*[59]

18. ស.ច.ស បានសម្រេចដោយត្រឹមត្រូវថា ការចេញដីកាដំណោះស្រាយផ្ទុយគ្នា ក្នុងសំណុំរឿង ០០៤ មិនត្រូវបានហាមឃាត់នោះឡើយ នៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[60]។ ទីមួយ ការសម្រេចរបស់ អ.ប.ជ ដែលថា គួរតែចេញដីកាដំណោះស្រាយតែមួយ[61] គឺបំពានទៅលើភារកិច្ចដោយឯករាជ្យ របស់ ស.ច.ស[62] និងតម្រូវឱ្យ ស.ច.ស មួយរូប រំលោភបំពានទៅលើភារកិច្ចនេះ ដោយសុខចិត្តសម្របទៅតាមគោលជំហរផ្ទុយគ្នាទាំងស្រុងរបស់ដៃគូរគាត់។ ជាជម្រើសមួយទៀត ការនេះផ្តល់តម្លៃដោយមិនអាចអនុញ្ញាតបាន ទៅលើទម្រង់ជាជាងទៅលើខ្លឹមសារ ដោយតម្រូវថា ភាពខុសគ្នាដែលមិនអាចផ្សះផ្សារបាន ដែលទាមទារឲ្យមានឯកសារពីរត្រូវប្រកាសចេញជាឯកសារតែមួយ[63]។

19. បន្ថែមលើនេះ អង្គការសហប្រជាជាតិ ("អ.ស.ប") និង រាជរដ្ឋាភិបាលកម្ពុជា បានប្រមើលមើលពីលទ្ធភាពដែលថា ស.ច.ស ដែលឯករាជ្យនិងមានឋានៈស្មើគ្នា នឹងខ្វែងយោបល់គ្នា ហើយបានកំណត់យន្តការដែលអាចអនុញ្ញាតបាន សម្រាប់ការដោះស្រាយជាមួយការខ្វែងយោបល់បែបនេះ

---

[58] បណ្តឹងសាទុក្ខ របស់ ស.ព.អ កថាខណ្ឌ ៣៦-៥៧។

[59] បណ្តឹងសាទុក្ខ របស់ ស.ព.អ កថាខណ្ឌ ១៨-២០, ៣៦-៤៤។

[60] សំណុំរឿង ០០៤/២-ឯកសារ **D355/1** ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ("ដីកាសម្រេចលើការដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងការខ្វែងយោបល់") កថាខណ្ឌ ១៤-១៦។ សូមមើលផងដែរ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ៤២-៤៤ ដែលផ្តល់នូវការវិភាគទៅលើប្រព័ន្ធជដែកសួរដេញដោលនៅថ្នាក់ជាតិ និងអន្តរជាតិ និងគូសបញ្ជាក់ពីលក្ខណៈពិសេសនៃក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ដែលអនុញ្ញាតឲ្យចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា។

[61] ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា កថាខណ្ឌ ១១០ (ឯកច្ឆន្ទ)។

[62] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៣៦-៣៧ *ដកស្រង់* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៣(៣), ៥(៣) និង ច្បាប់ អ.វ.ត.ក មាត្រា ១០ ថ្មី, ២៥។

[63] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៣៧។

[64]។ តាមពិតទៅ លទ្ធភាពនៃការចេញដីកាដំណោះស្រាយពីរ ក្នុងករណីមានភាពខុសគ្នាមិនអាចផ្សះផ្សារបាន ត្រូវបាន អ.ជ.ត.ក ទទួលស្គាល់ នៅក្នុងសំណុំរឿង ០០៤/២ ដែលអង្គជំនុំជម្រះបានរៀបរាប់អំពីសេណារីយ៉ូនេះថា "សឹងតែមិនអាចជៀសវាងបាន"[65]។ សំណុំរឿង ០០៤ ក៏មិនខុសគ្នាដែរ[66]។

20. ហេតុដូច្នេះពាក្យពេចន៍នៃវិធានផ្ទៃក្នុង ដូចជាវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង យោងទៅរកការចេញដីកាដំណោះស្រាយតែមួយ ចាំបាច់ត្រូវបកស្រាយក្នុងបរិបទនេះ ហើយបកស្រាយរួមជាមួយវិធាន ១(២) នៃវិធានផ្ទៃក្នុង ដែលចែងយ៉ាងច្បាស់ថា ការយោងទៅរក ស.ច.ស គឺរួមបញ្ចូលទាំង ស.ច.ស ទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និង ស.ច.ស ណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ[67]។ កិច្ចកន្លងមករបស់ ស.ច.ស នៅក្នុងសំណុំរឿងនេះ មិនអាចត្រូវបានធ្វើមោឃភាព ដោយសារតែការបកស្រាយផ្ទុយនាពេលថ្មីៗនេះរបស់ អ.ប.ជ ទៅលើវិធានផ្ទៃក្នុង ជាពិសេសដោយផ្អែកទៅលើការដែល អ.ប.ជ មិនបានបំពេញកិច្ច នៅពេលទទួលបានការជូនដំណឹង អំពីចេតនារបស់ ស.ច.ស ក្នុងការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា[68]។

---

[64] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ១៨-២០ *ដកស្រង់* កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥(៤), ៧(១), ច្បាប់ អ.វ.ត.ក មាត្រា ១៤ថ្មី(១), ២៣ ថ្មី, វិធាន ៧២(១)-(២)) ២៨-៣០, ៣៨-៣៩ នៃវិធានផ្ទៃក្នុង។ បទប្បញ្ញត្តិមានភាពអនុគ្រោះយ៉ាងច្បាស់ក្រឡែត និងមិនធ្វើការដោះស្រាយការខ្វែងយោបល់គ្នា មុនការចេញដីកាដំណោះស្រាយ។

[65] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤០ *ដកស្រង់* សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥៩ (សម្រង់), ៦២។

[66] *សូមមើលឧទាហរណ៍* ឯកសារ **D382** ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ ៣, ៧, ២១ ដែលកត់សម្គាល់ថា ស.ច.ស បានចុះបញ្ជីការខ្វែងយោបល់គ្នានៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣, ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥, ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០១៨។ ឯកសារ **D1/1.3** ឧបសម្ព័ន្ធ ១៖ សំណៅសាធារណៈមានកោសលុប៖ ការពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ ១ ដែលកត់សម្គាល់ថា នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ ស.ព.អ បានរាយការណ៍ថា សហព្រះរាជអាជ្ញាជាតិមិនយល់ព្រមកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរថ្មីៗទេ និងបដិសេធមិនចុះហត្ថលេខាលើដីកាសន្និដ្ឋានទាំងនេះ។

[67] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤១។

[68] សំណុំរឿង ០០៤/២-ឯកសារ **D355/1** ដីកាសម្រេចលើការដាក់បង្ហាញឯកសារពាក់ព័ន្ធនឹងការខ្វែងយោបល់ កថាខណ្ឌ ១៣-១៨។

### *២) ដីកាដំណោះស្រាយផ្ទុយគ្នា មិនមោឃៈ និងអសុពលភាពឡើយ បើទោះបីជាការចេញក្នុងពេលដំណាលគ្នារបស់វាខុសច្បាប់ក្តី*[69]

21. ដោយលើកឡើងវិញនូវការសម្រេច របស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២[70] យឹម ទិត្យ បាន អះអាងដោយខុសឆ្គងថា "មិនមានការជំទាស់" ឡើយ ដែលថា ដីកាដំណោះស្រាយគឺមោឃៈ និង អសុពលភាព ដោយសារតែសេចក្តីសម្រេចរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយ ទាំងនេះក្នុងពេលជាមួយគ្នា គឺជារឿងខុសច្បាប់[71]។ ដូចបានពិភាក្សាខាងលើ ដីកាបញ្ជូនរឿង ទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤ នៅតែមានសុពលភាព ហើយសំណើនេះ តាមពិតទាមទារឱ្យ ស.ច.ស *ធ្វើឱ្យ* វាទៅជាមោឃៈ និងអសុពលភាព បន្ទាប់មកបញ្ចប់រឿងក្តីនេះ។ ការអះអាងនេះ ត្រូវតែបរាជ័យ ដោយហេតុថា ស.ច.ស មិនត្រឹមតែគ្មានអំណាចធ្វើមោឃភាពដីកាដំណោះ ស្រាយរបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងសេចក្តីសម្រេចក្នុងសំណុំរឿង ០០៤/២ មិនអាចផ្ទេរចូល មកក្នុងសំណុំរឿង ០០៤ បានទេ ដែលដូចក្នុងករណីនៅទីនេះ មានមូលហេតុច្បាស់លាស់ ក្នុងការងាកចេញពីវា[72]។

22. សម្រាប់គោលបំណងវែកញែក បើទោះបីជាការចេញដីកាដំណោះស្រាយផ្ទុយគ្នា គឺជាការ រំលោភបំពានទៅលើ ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក តែនេះគឺជាកំហុសឆ្គងនីតិវិធី ដែលមិនធ្វើ ឱ្យមោឃភាពដល់ដីកាដំណោះស្រាយឡើយ[73]។ ជាចំនុចចាប់ផ្តើម មានការកំណត់ច្បាស់លាស់នៅ តាមតុលាការអន្តរជាតិ រួមទាំង អ.វ.ត.ក ផងដែរថា កំហុសឆ្គងនីតិវិធី មិនបានបណ្តាលឱ្យកិច្ច ដែលជាលទ្ធផលនោះ មោឃៈនិងអសុពលភាព ដោយស្វ័យប្រវត្តិឡើយ។ ដីកាដំណោះស្រាយ

---

[69] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២១-២៤, ៤៥-៥១។

[70] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦៧។ សូមមើលផងដែរ កថាខណ្ឌ ៥៣។

[71] ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ១៣-១៧ (សម្រង់នៅកថាខណ្ឌ ១៤), ៣៩។ សំណើរបស់សហព្រះរាជអាជ្ញា អន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង។

[72] *សូមមើល* កថាខណ្ឌ ៧, ១១-១៧ *យោងខាងលើ*។

[73] *ផ្ទុយពី* ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ១៦ *ដកស្រង់* សំណុំរឿង ០០៣-ឯកសារ **D270/7** សេចក្តីសម្រេច លើសំណើសុំបញ្ជូនសំណុំរឿង កថាខណ្ឌ ២១។

*មិនមាន*មោឃភាពជាប់មកជាមួយឡើយ[74]។ ផ្ទុយទៅវិញ កំហុសឆ្គងនីតិវិធីចាំបាច់ត្រូវពិនិត្យតាមករណីជាក់ស្តែង និងជាញឹកញាប់មិនមែនជាកំហុសឆ្គងស្លាប់រស់នោះទេ តែវាអាចកែតម្រូវបាន[75] ដូចជាករណីនេះជាដើម។ នៅក្នុងសំណុំរឿង ០០៤ ការចោទប្រកាន់ពីការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា ត្រូវបានកែតម្រូវដោយ សេចក្តីពិចារណារបស់ អ.ប.ជ ទៅលើអង្គសេចក្តីនៃដីកាដំណោះស្រាយនីមួយៗ[76]។

23. បន្ថែមលើនេះ មានការចែងច្បាស់នៅក្នុងច្បាប់ថា មិនមែនរាល់កំហុសឆ្គងនីតិវិធីមុនពេលជំនុំជម្រះទាំងអស់ អាចរារាំងសំណុំរឿងមួយ មិនឱ្យបន្តកិច្ចដំណើរការនីតិវិធីឡើយ[77]។ ដើម្បីសម្រេចថាឧបាស្រ័យអ្វីដែលសមស្រប សម្រាប់ព្យសនកម្មណាមួយ ដែលបង្ករឡើងដោយកំហុស

---

[74] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២១ (និងយុត្តិសាស្ត្រដែលបានដកស្រង់នៅខាងក្នុង), ៤៥។ *សូមមើលជាពិសេស* សេចក្តីសម្រេចនាពេលកន្លងរបស់អង្គជំនុំជម្រះទាក់ទងនឹងអានុភាពនេះនៅក្នុងសំណុំរឿង ០០២-ឯកសារ **F36** សាលដីកា កថាខណ្ឌ ១០០ ដែល ចៅក្រមអន្តរជាតិនៃ អ.ប.ជ បានយោងយ៉ាងត្រឹមត្រូវនៅក្នុងបរិបទនេះ (សូមមើល ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ ជើងទំព័រ ៦០៩ ជើងទំព័រ ៣៣៨)។ *សូមមើលផងដែរ* ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៦៤ ("អង្គហេតុដែលថា *សកម្មភាពមួយចំនួន* របស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយទាំងនេះ គឺជាការខុសច្បាប់ មិនអាច "ផ្តល់ភាពសមស្រប" ក្នុងការឈានទៅរកការសន្និដ្ឋានទូទៅដោយគ្មានការបង្ហាញសមហេតុផលអំពីមូលដ្ឋាន ដែលភាពខុសច្បាប់ផ្នែកនីតិវិធីនោះ នាំឱ្យប៉ះពាល់ទាំងស្រុងដល់ដីកាដំណោះស្រាយទាំងនោះឡើយ"), ១៦៥, ១៦៦ ("ចៅក្រមអន្តរជាតិមិនជឿជាក់ថា វាជាគោលការណ៍ទូទៅនៃច្បាប់ ដែលអនីត្យានុកូលភាពផ្នែកនីតិវិធីជាស្វ័យប្រវត្តិ និងជានិច្ចកាលនាំឱ្យមានមោឃភាពនោះឡើយ")។ សំណុំរឿង ០០៣-ឯកសារ **D266/27 & D267/35** សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២៦៣-២៨៣ ជាពិសេស កថាខណ្ឌ ២៧១ (អ.ជ.ត.ក បកស្រាយមិនត្រឹមត្រូវនូវជំហរជាឯកច្ឆន្ទរបស់ អ.ប.ជ ពេលដែល អ.ជ.ត.ក កំណត់ប្រភេទជំហរនេះថាជាការប្រកាសផ្លូវច្បាប់អំពី "មោឃភាព"), ២៧២-២៧៣, ២៨១ ("សរុបមក សេចក្តីពិចារណាជាឯកច្ឆន្ទរបស់អង្គបុរេជំនុំអាចត្រូវបានយល់ដឹងដោយស្មោះត្រង់ដូចតទៅ៖ [...] (២) អង្គបុរេជំនុំជម្រះ*មិនបាន*សម្រេចថា ដីកាដំណោះស្រាយទាំងពីរមោឃៈ និងអសុពលភាពឡើង បើទោះបីជាមានសកម្មភាពដោយខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេត ដោយសារតែចៅក្រមរបស់អង្គបុរេជំនុំជម្រះបានជឿជាក់ថា យ៉ាងហោចណាស់មានដីកាដំណោះស្រាយមួយដែលមានសុពលភាព")។

[75] សូមមើល បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២២-២៣, ៤៥។ សំណុំរឿង ០០២-ឯកសារ **F36** សាលដីកាក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១០០។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៦៤, ១៦៦។

[76] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤៥, ៤៧។

[77] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២១-២៤, ៤៧។

ឆ្លងបែបនេះ ចាំបាច់ត្រូវតែពិចារណាទៅលើកត្តាមួយចំនួនរួមមាន ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ផលប្រយោជន៍ និងសិទ្ធិ របស់ភាគីទាំងអស់ និងសមាមាត្រនៃឧបាស្រ័យណាមួយ ចំពោះព្យសនកម្មដែលបានចោទឡើង[78]។ ការវាយតម្លៃបែបនេះបង្ហាញច្បាស់ថា ការបញ្ចប់សំណុំរឿង មិនមានយុត្តិកម្មឡើយ។

24. ទីមួយ ដើម្បីកំណត់ការទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងការជំនុំជម្រះដោយយុត្តិធម៌ និងមិនលម្អៀង ដែលគោរពសិទ្ធិរបស់ភាគី*ទាំងអស់*នោះ គឺមិនអាចបង្ករផលប៉ះពាល់សំខាន់ទៅលើ យឹម ទិត្យ ឡើយ[79]។ ទីពីរ ជនរងគ្រោះ ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ សុទ្ធតែមានចំណាប់អារម្មណ៍សំខាន់ ក្នុងការជំនុំជម្រះលើបុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរបំផុត[80]។ ទីបី ការបិទបញ្ចប់កិច្ចដំណើរការនីតិវិធី គឺជាឧបាស្រ័យដ៏គំហុកមួយ ដែលគួរត្រូវបានអនុវត្ត តែក្នុងកាលៈទេសៈពិសេស ដែល "អាក្រក់" ឬ "គួរឲ្យស្អប់ខ្ពើម" ចំពោះរដ្ឋបាលតុលាការ ក្នុងការអនុញ្ញាតឲ្យកិច្ចដំណើរការនីតិវិធីបន្ត ឬក្នុងករណីដែលកំហុសឆ្គង បណ្តាលឲ្យសិទ្ធិរបស់ យឹម ទិត្យ ត្រូវបានរំលោភបំពាន ដល់កម្រិតដែលថា មិនអាចមានការជំនុំជម្រះប្រកបដោយយុត្តិធម៌បាន[81]។ លក្ខខណ្ឌតម្រូវខ្ពស់នេះ មិនត្រូវបានបំពេញបានឡើយក្នុងករណីនេះ ហើយការបញ្ចប់កិច្ចដំណើរការនីតិវិធីផ្អែកលើមូលដ្ឋាន ដែលមិនមានចែងក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺមិនអាចអនុញ្ញាតបានឡើយ ដូចដែល អ.ជ.ត.ក និង អ.ជ.ស.ដ បានបញ្ជាក់[82]។

---

[78] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២១, ២៣, ៤៦។

[79] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤៧-៤៨។

[80] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៥០ និងយុត្តិសាស្ត្រដែលត្រូវបានដកស្រង់នៅខាងក្នុង។

[81] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២៤ និងយុត្តិសាស្ត្រដែលត្រូវបានដកស្រង់នៅខាងក្នុង។

[82] *សូមមើល* បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៥៧។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អនុម័តថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ បកប្រែថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា៧ កម្រិតយ៉ាងច្បាស់អំពីមូលហេតុនៃការរលត់បណ្តឹងអាជ្ញា ក្រៅអំពីការលើកលែងចោទប្រកាន់ ឬការរួចខ្លួន ដែលឈរលើមូលដ្ឋាននៃអង្គសេចក្តី មកត្រឹមកាលៈទេសៈចំនួនប្រាំ (មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និង អាជ្ញាអស់ជំនុំ) ដែលពុំមានចំណុចមួយណាអាចអនុវត្តបានចំពោះសំណុំរឿង ០០៤ នេះឡើយ។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង គិតត្រឹមថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ មាត្រា៦។ សំណុំរឿង ០០២-ឯកសារ E138/1/10/1/5/7 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ

25. យឹម ទិត្យ មិនបានទទួលរងផលប៉ះពាល់សំខាន់ ឬព្យសនកម្មជាក់ស្តែង ដែលជាយុត្តិកម្មសម្រាប់ការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងរូបគាត់ឡើយ ហើយការអះអាងរបស់គាត់ថា "ការបន្តកិច្ចនីតិវិធីនឹងបង្កជាការរំលោភនីតិវិធី"[83] គឺមិនមានមូលដ្ឋានទាល់តែសោះ។ ទីមួយ សម្រាប់មូលហេតុដូចបានពិភាក្សាខាងលើ សិទ្ធិរបស់ យឹម ទិត្យ ក្នុងការទទួលបានការប្រព្រឹត្តស្មើភាពគ្នា និងសច្ចភាពផ្លូវច្បាប់ មិនត្រូវបានរំលោភបំពានដោយការបញ្ជូនគាត់ទៅជំនុំជម្រះ ផ្អែកលើបទចោទនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[84]។ ទីពីរ មិនមានការពន្យាពេលមិនសមហេតុផលឡើយក្នុងសំណុំរឿងនេះ ដូចគាត់បានចោទឡើយ។ រឿងក្តី *Marini តទល់នឹង Albania* ដែលគាត់ពឹងផ្អែកលើ សម្រាប់សិទ្ធិទទួលបាន ការសម្រេចស្ពាពរនិងឆាប់រហ័ស លើសំណុំរឿងរបស់គាត់នោះ[85] ក៏បានគាំទ្រផងដែរថា ការពន្យាពេលអាចផ្តល់ជាយុត្តិកម្មបានផងដែរ ក្នុងកាលៈទេសៈជាក់លាក់ណាមួយ បើទោះបីជាពួកគេ "មិនអាចទៅជាដូច្នេះបាន ដោយធ្វើឲ្យខូចខាតដល់ធាតុផ្សំសំខាន់នៃសិទ្ធិដែលត្រូវបានការពារ"[86]។ ហេតុដូច្នេះរឿងក្តីទាំងនោះ ត្រូវធ្វើការសម្រេចនៅក្នុងពេលវេលា*សមស្រប* ដោយមិនមានការពន្យាពេលដោយ*មិនសមហេតុផល*។ ការណ៍នេះស្របជាមួយពាក្យពេចន៍សាមញ្ញ នៃវិធាន ២១(៤) នៃវិធានផ្ទៃក្នុង លិខិតុបករណ៍សិទ្ធិមនុស្ស និងយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ[87]។

---

ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-ឯកសារ **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧ (សម្រេចថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក អាចនឹងត្រូវបានបញ្ចប់តែដោយផ្អែកលើមូលដ្ឋានដ៏មានកម្រិតដែលមានចែងក្នុង មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា តែប៉ុណ្ណោះ)។

[83] ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ៤៥។

[84] *សូមមើល* កថាខណ្ឌ ១១-១៧ *យោងខាងលើ*។

[85] អះអាងអំពីសិទ្ធិនោះនៅក្នុង ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ១, ៩, ៤០-៤១ និង *ដកស្រង់ Marini ទល់នឹង Albania,* No. 3738/02, សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ (*"Marini")* កថាខណ្ឌ ១២០-១២៣ ក្នុងជើងទំព័រ ១៥, ១៧, ១៨ ដើម្បីគាំទ្រសិទ្ធិនោះ។ *សូមមើលផងដែរ* ជើងទំព័រ ១០៧ *ដកស្រង់* សំណុំរឿង ០០៣-ឯកសារ **D270/7** សេចក្តីសម្រេចលើសំណើសុំបញ្ជូនសំណុំរឿង កថាខណ្ឌ ២៦ ដែលពិភាក្សាពីរឿងក្តី *Marini ត* ទៅវិញ។

[86] រឿងក្តី *Marini* កថាខណ្ឌ ១២៦។

[87] ការដែល យឹម ទិត្យ ផ្អែកលើបញ្ញើសំអាងផ្លូវច្បាប់ដែលមានរាយក្នុងឯកសារ **D386** សំណើសុំបញ្ចប់ ជើងទំព័រ ១៥ និង ១១០ ដើម្បីគាំទ្រដល់ការអះអាងពីសិទ្ធិទទួលបានការសម្រេចចិត្តចុងក្រោយ "លឿន" លើសំណុំរឿងរបស់គាត់ គឺមិនត្រឹមត្រូវទេ។ *សូមមើលឧទាហរណ៍* វិធាន ២១(៤) នៃវិធានផ្ទៃក្នុង ("ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះត្រូវ

26. ការវាយតម្លៃទៅលើអ្វីដែល "*មិនសមហេតុផល*" ចាំបាច់ត្រូវធ្វើឡើង "ផ្អែកលើកាលៈទេសៈ" នៃរឿងក្តី ដែលក្នុងចំណោមកត្តានានា មានផងដែរនូវភាពស្មុគ្រស្មាញអង្គហេតុនិងអង្គច្បាប់ នៃកិច្ចដំណើរការនីតិវិធី[88]។ យឹម ទិត្យ បានទទួលស្គាល់ដោយត្រឹមត្រូវ អំពីភាពស្មុគ្រស្មាញ

---

ធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"), ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី ដែលចែងដោយមិនត្រឹមត្រូវ "to be tried without delay" ជាសំណៅជាភាសាអង់គ្លេស ប៉ុន្តែត្រឹមត្រូវនៅក្នុងសំណៅជាភាសាបារាំង "À être jugée sans retard *excessif*" (គូសបញ្ជាក់បន្ថែម), កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(គ) ("ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ [...] ត្រូវ(គ) ត្រូវបានជំនុំជម្រះ*ដោយឥតពន្យារពេលយូរហួសហេតុ*" (គូសបញ្ជាក់បន្ថែម))។ អនុសញ្ញា (អឺរ៉ុប) ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ទីក្រុងរ៉ូម ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ លេខ 213 UNTS 221 (ដូចដែលត្រូវបានធ្វើវិសោធនកម្ម) មាត្រា ៦(១) ("មានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងត្រឹមត្រូវនៅក្នុងរយៈពេលមួយសមស្រប", ធម្មនុញ្ញអាហ្វ្រិក (Banjul) ស្តីពីសិទ្ធិមនុស្ស និងប្រជាជន ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ លេខ CAB/LEG/67/3 rev. 5, 21 I.L.M. 58 (1982), មាត្រា ៧(១)(ឃ) ("សិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប"), អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស "កិច្ចព្រមព្រៀង San José, Costa Rica"San José ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ 1144 UNTS 143 មាត្រា ៨(១) ("សិទ្ធិទទួលបានការជំនុំជម្រះ [...] នៅក្នុងរយៈពេលមួយសមស្រប"), លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦៧(១)(គ) ("ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលដោយមិនសមស្រប"), រឿងក្តី *Frydlender តទល់នឹងប្រទេសបារាំង សំណុំរឿងលេខ* ៣០៩៧៩/៩៦ សាលក្រម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ ("រឿងក្តី *Frydlender*") កថាខណ្ឌ ៤៥ ("សិទ្ធិទទួលបានការធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងរយៈពេលមួយសមស្រប")។ សូមមើលផងដែរ រឿងក្តី *Halilović* សំណុំរឿងលេខ IT-01-48-A សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦ ("សេចក្តីសម្រេចលើសវនាការលើបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តី *Halilović*") កថាខណ្ឌ ១៧ "សិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលដោយមិនសមស្រប មិនការពារប្រឆាំងការពន្យារពេល*ណាមួយ*នៅក្នុងកិច្ចដំណើរការនីតិវិធីទេ ប៉ុន្តែ ការពារមិនឱ្យមានការពន្យារពេល*ដោយមិនសមស្រប*" (គូសបញ្ជាក់បន្ថែម))។ រឿងក្តី *Nyiramasuhuko និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-98-42-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកាក្នុងរឿងក្តី *Nyiramasuhuko*") កថាខណ្ឌ ៣៦៤។

[88] *សូមមើលឧទាហរណ៍* ចក្តីសម្រេចលើសវនាការលើបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តី *Halilović* កថាខណ្ឌ ១៧។ សាលដីកាក្នុងរឿងក្តី *Nyiramasuhuko* កថាខណ្ឌ ៣៦០, ៣៦២។ រឿងក្តី *Renzaho* សំណុំរឿងលេខ ICTR-97-31-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៣៨។ រឿងក្តី *Šešelj* សំណុំរឿងលេខ IT-03-67-T សេចក្តីសម្រេចលើបណ្តឹងផ្ទាល់មាត់របស់ជនជាប់ចោទពីការបំពានកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ("សេចក្តីសម្រេចលើការបំពានកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Šešelj*") កថាខណ្ឌ ៣០។ រឿងក្តី *Ayyash និងអ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/T/TC សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៩៦៦។

និងទំហំធំធេង នៃសំណុំរឿង ០០៤[89] ហើយដែលគាំទ្របន្ថែមទៀតផងដែរដោយ ចំនួននៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងរូបគាត់ ទម្រង់នៃការទទួលខុសត្រូវផ្សេងៗគ្នា វិសាលភាពភូមិសាស្ត្រនិងពេលវេលានៃសំណុំរឿង និងបរិមាណនៃភស្តុតាងនៅក្នុងសំណុំរឿង[90]។

27. ការវិភាគលើការពន្យាពេលដោយមិនសមហេតុផល ក៏ចាំបាច់ត្រូវថ្លឹងថ្លែងផងដែរអំពី ព្យសនកម្មដែលចោទឡើងនានា ធៀបទៅនឹង "ភាពចាំបាច់ទូទៅនៃការស៊ើបអង្កេត និងដំណើរការតុលាការដែលត្រូវជម្រុញ"[91]។ ក្នុងន័យនេះ មានការពិចារណាសំខាន់ៗចំនួនបួន នៅក្នុងសំណុំរឿង ០០៤។

---

[89] *សូមមើលឧទាហរណ៍* ឯកសារ **D361/3** ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំពេលវេលាសម្រាប់រៀបចំឱ្យបានគ្រប់គ្រាន់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ៤ (កត់សម្គាល់ដែរថា វាមិនយុត្តិធម៌ទេក្នុងការប្រញាប់បិទការស៊ើបសួរដោយមិនផ្តល់ឱកាសសមស្របឱ្យគាត់ចូលរួម)។

[90] *សូមមើលឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥១, ៩៩២-១០៤០ ទំព័រ ៤៧៥-៤៨៧ ដែលរៀបរាប់លម្អិតនូវឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលបានកើតឡើងនៅទីតាំងចំនួនជាង ២០ កន្លែងនៅភូមិភាគនិរតី និងពាយ័ព្យ មុខតំណែងផ្សេងៗរបស់ យឹម ទិត្យ ក្នុងជួរថ្នាក់ដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទម្រង់ជាច្រើននៃការទទួលខុសត្រូវ រួមមាន សមាជិកនៃសហឧក្រិដ្ឋកម្មរួមបីផ្សេងគ្នា)។ ឯកសារ **D384** ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ២ (កត់សម្គាល់ថា មនុស្សចំនួន ២០១៤ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង ០០៤)។ ស.ព.អ កត់សម្គាល់បន្ថែមទៀតថា មុនពេលបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤ យឹម ទិត្យ គឺជាជនត្រូវចោទម្នាក់ក្នុងចំណោមជនត្រូវចោទបីនាក់។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានប្តឹងទៅ ស.ច.ស ក្នុងចំណោមរឿងផ្សេងទៀត អំពីការបោសសំអាត ដែលផ្តោតលើខ្មាំងផ្ទៃក្នុង នៅក្នុងភូមិភាគកណ្តាល និងភូមិភាគពាយ័ព្យ ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ចាម (ក្នុងភូមិភាគកណ្តាល) និង ខ្មែរក្រោម (ក្នុងភូមិភាគពាយ័ព្យ) និងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងទីតាំងជាច្រើន។ *សូមមើលផងដែរ* ឯកសារ **D378/2.3** ឧបសម្ព័ន្ធ ខ – ប្រវត្តិនីតិវិធី ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១-៣ (កម្មវត្ថុ៖ វិសាលភាពនៃបណ្តឹង) កថាខណ្ឌ ១២ (កម្មវត្ថុ៖ ការបំបែកសំណុំរឿង) កថាខណ្ឌ ១៦ (កម្មវត្ថុ៖ បរិមាណនៃភ័ស្តុតាង)។

[91] *សូមមើលឧទាហរណ៍* សំណុំរឿង ០០២-ឯកសារ **D314/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៧០។ សំណុំរឿង ០០៣-ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ យោបល់របស់ចៅក្រម Beauvallet និងចៅក្រម Baik ("ចៅក្រមដែលបានចុះហត្ថលេខា") ទាក់ទងនឹងអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៦។ *Boddaert ទល់នឹង ប្រទេសបែលហ្ស៊ិក* No. 12919/87, សាលក្រម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២ កថាខណ្ឌ ៣៩ ("មាត្រា ៦ [...] បង្គាប់ថា កិច្ចដំណើរការនីតិវិធីតុលាការត្រូវតែឆាប់រហ័ស ប៉ុន្តែវាក៏មានគោលការណ៍ទូទៅជាងនេះនៃរដ្ឋបាលតុលាការត្រឹមត្រូវផងដែរ។") បានអនុវត្តនៅ

ទីមួយ យឹម ទិត្យ មិនដែលត្រូវបានឃុំឃាំងឡើយ[92]។ ទីពីរ បទចោទប្រឆាំងរូបគាត់ គឺមានភាពធ្ងន់ធ្ងរខ្លាំងបំផុត[93]។ ទីបីអាណត្តិរបស់ អ.វ.ត.ក គឺត្រូវនាំយកមកជំនុំជម្រះនូវបុគ្គលទាំងឡាយណា ដែលស្ថិតក្នុងយុត្តាធិការរបស់ខ្លួន[94]។ ទីបួន និងប្រហែលជាកត្តាសំខាន់បំផុតនោះគឺ អ.ប.ជ បានសម្រេចជាឯកច្ឆន្ទថា ការពន្យាពេលដែលបណ្តាលមកពី ការមិនបានគោរពដោយម៉ត់ចត់ របស់ ស.ច.ស ទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបាន "ធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់យុត្តិធម៌ នៃកិច្ចដំណើរការនីតិវិធី ដែលជាភាពអយុត្តិធម៌ក្នុងការបន្ត" ហើយរយៈពេលទាំងស្រុង នៃសំណុំរឿង ០០៤ ក៏មិនបានបង្ហាញគ្រប់គ្រាន់ថា ការជំនុំជម្រះប្រកបដោយយុត្តិធម៌ដោយអង្គជំនុំ អ.ជ.ស.ដ គឺមិនអាចធ្វើទៅបាន ឬខូចខាតដោយមិនអាចជួសជុលបាន[95]។ និយាយដោយខ្លី គឺមិនមានការពន្យាពេលដោយមិនសមហេតុផល និងមិនមានព្យសនកម្មដែលបង្ករឡើងដោយការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នាឡើយ។ នៅពេលថ្លឹងថ្លែងលើការសម្រេចនេះ ធៀបទៅនឹងសេចក្តីពិចារណាដទៃទៀត ការថ្លឹងថ្លែងគឺធ្ងន់ខ្លាំងទៅលើ ការជម្រុញសំណុំរឿង ០០៤ ទៅជំនុំជម្រះ មិនមែនបិទបញ្ចប់ឡើយ។

---

ក្នុង *Coëme និងគូកន ទល់នឹង ប្រទេសបែលស៊ិក* Nos 32492/96, 32547/96, 32548/96, 33209/96, 33210/96, សាលក្រម ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៤០។

[92] អត្ថាធិប្បាយទូទៅលេខ ៣២ កថាខណ្ឌ ៣៥។ រឿងក្តី *Abdoella តទល់នឹងប្រទេសហូឡង់* សំណុំរឿងលេខ ១២៧២៨/៨៧ សាលក្រម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩២ កថាខណ្ឌ ២៤ ("ការឃុំឃាំងជាកត្តាមួយដែលត្រូវយកមកពិចារណានៅក្នុងការវាយតម្លៃថាតើ លក្ខខណ្ឌតម្រូវនៃការធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តី នៅក្នុងរយៈពេលមួយសមស្រប ត្រូវបានបំពេញឬយ៉ាងណា")។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា កថាខណ្ឌ ៥២០។

[93] *សូមមើលឧទាហរណ៍* រឿងក្តី *Rwamakuba* សំណុំរឿងលេខ ICTR-98-44C-PT សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ កថាខណ្ឌ ១៩ ("ភាពសមហេតុផលនៃរយៈពេលកិច្ចដំណើរការនីតិវិធីត្រូវធ្វើការវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើកត្តាមួយចំនួនរួមមាន៖ ភាពធ្ងន់ធ្ងរនៃបទចោទប្រឆាំងនឹងជនជាប់ចោទ")។ សេចក្តីសម្រេចលើការបំពានកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Šešelj* កថាខណ្ឌ ២៩-៣០។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ ៤៧៥-៤៨៧ (ដាក់បន្ទុកលើ យឹម ទិត្យ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦)។

[94] ច្បាប់ អ.វ.ត.ក មាត្រា ១, ២ ថ្មី។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។

[95] ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា កថាខណ្ឌ ៧៣-៧៩ (សម្រង់ត្រង់កថាខណ្ឌ ៧៨)។ កត់សម្គាល់ថា សេចក្តីសម្រេចនេះត្រូវចេញ រយៈពេល ៣០ ថ្ងៃ មុនឯកសារ **D386** សំណើសុំបញ្ចប់ ធ្វើការស្នើសុំពន្យារពេលដូចគ្នាម្តងទៀត។

28. ហេតុដូច្នេះគឺជាភាពមិនសមមាត្រទាល់តែសោះ ក្នុងការបញ្ចប់សំណុំរឿង ០០៤ នៅពេលដែលការចេញដីកាដំណោះស្រាយផ្ទុយគ្នា មិនបានបណ្ដាលឱ្យមានផលប៉ះពាល់សំខាន់ណាមួយ និងមិនបានដកហូតពី យឹម ទិត្យ នូវសិទ្ធិស្របច្បាប់ណាមួយនោះ[96]។ សេចក្ដីសម្រេចបែបនេះ គឺមិនបានគិតពិចារណាទាល់តែសោះ ចំពោះក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ច្បាប់ដែលបានកំណត់ស្ដីពីឧបាស្រ័យសមស្រប សម្រាប់កំហុសឆ្គងនីតិវិធី និងសិទ្ធិជាសារវន្ត និងផលប្រយោជន៍របស់ភាគីដែលកត្តាទាំងអស់នេះតម្រូវ ឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ ទៅលើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ដែលបានចោទប្រកាន់ទៅលើ យឹម ទិត្យ។

### *៣) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុប[97]*

29. ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤ មិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុប (ហើយ ដីកាសម្រេចលើកលែងចោទប្រកាន់ មិនមានសំឡេងភាគច្រើនលើសលុប *តម្កល់*សុពលភាពដែល)[98]។ ហេតុដូច្នេះសំណុំរឿងត្រូវទៅជំនុំជម្រះ ដោយផ្អែកលើអ្វីដែល អ.ប.ជ បានរៀបរាប់ជាឯកច្ឆន្ទថាជា គោលជំហរស្វ័យប្រវត្តិ "ជាសារវន្តនិងកំណត់សម្រេច" ដែលថា "ការស៊ើបអង្កេតត្រូវបន្ត"[99] ជាគោលការណ៍ស្នូលដែលចៅក្រមអន្តរជាតិ នៃ អ.ប.ជ បានកំណត់ដោយត្រឹមត្រូវថា "គោលការណ៍បន្តកិច្ចស៊ើបសួរ និងការជំនុំជម្រះ"[100]។ ការមិនអនុវត្តគោលការណ៍តម្រូវនេះ មិនធ្វើប្រឆាំងទៅនឹងអាណត្តិនោះឡើយ វាគ្រាន់តែបង្ហាញអំពីកំហុសអង្គច្បាប់ប៉ុណ្ណោះ។

---

[96] បណ្ដឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤៨, ៥០-៥១, ៧៣។ *ផ្ទុយពី* ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ៤៥, ៤៧។

[97] បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ កថាខណ្ឌ ២៥-៣០, ៥២-៥៧។

[98] ឯកសារ **D381/45 & D382/43** សេចក្ដីពិចារណា ទំព័រ ៤៩-៥០ (ផ្នែកសម្រេចសេចក្ដី) យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៧៤-១៧៦, ៥៣៩ ទំព័រ ៣៥០ (ផ្នែកសម្រេចសេចក្ដី)។

[99] ឯកសារ **D381/45 & D382/43** សេចក្ដីពិចារណា កថាខណ្ឌ ១០០, ១០៤ ជើងទំព័រ ២២៣។ គោលការណ៍នេះត្រូវបានបញ្ជាក់នៅក្នុងមាត្រា ៥(៤) និង ៧(៤) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ដែលត្រូវបានរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទទួលយក មានបញ្ជាក់នៅក្នុងមាត្រា ២៣ថ្មី នៃច្បាប់ អ.វ.ត.ក និងត្រូវបានអនុវត្តយ៉ាងទៀងទាត់នៅ អ.វ.ត។ល។

[100] ឯកសារ **D381/45 & D382/43** សេចក្ដីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៦៨, ១៧៤, ៥៣៣, ៥៣៨។ សូមមើលផងដែរ សំណុំរឿង ០០៣-ឯកសារ **D266/27 & D267/35** សេចក្ដីពិចារណាក្នុងសំណុំរឿង ០០៣ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ២៥៦, ២៦១។ សំណុំរឿង ០០៤/២-ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណាក្នុងសំណុំរឿង ០០៤/២ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៣២០។

30. ដោយអនុវត្តគោលការណ៍បន្ត វិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធពិសេសជាមួយ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានអនុភាពជាវិធានច្បាប់ពិសេស លើវិធានទូទៅនៃ វិធាន ៧៧ (១៣)(ក) នៃវិធានផ្ទៃក្នុង ដែលពាក់ព័ន្ធដីកាសម្រេចដទៃទៀតទាំងអស់។ ប្រសិនបើអ្នកតាក់តែងវិធានផ្ទៃក្នុង មានចេតនាថា ដីកាសម្រេចលើកលែងចោទប្រកាន់ បិទបញ្ចប់សំណុំរឿង ដោយមិនមានសំឡេងភាគច្រើនលើសលុប បដិសេធដីកាសម្រេចនោះទេ អ្នកតាក់តែងពិតជាបញ្ជាក់ដោយច្បាស់លាស់បែបនេះហើយ[101]។ ដូច្នេះបើទោះបីជាក្នុងស្ថានភាពដែល ដីកាសម្រេចលើកលែងចោទប្រកាន់ មានអានុភាពស្របគ្នាជាមួយ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដែលមិនមែនជាករណីបច្ចុប្បន្ននេះ) ក្តី សំណុំរឿងនៅតែបន្តទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋាននៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយសារតែកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក តែករណីដែលសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ បដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ[102]។

31. ការមិនគោរពគោលការណ៍បន្ត នឹងបង្កើតបានជា "ការរំលោភបំពាន ទាំងទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា"[103] រួមទាំងគោលការណ៍គោលដែលថា កិច្ចដំណើរការនីតិវិធី ចាំបាច់ត្រូវអនុលោមទៅតាម នីត្យានុកូលភាព ភាពយុត្តិធម៌ និងប្រសិទ្ធភាព។ ស.ព.អ យល់ស្របជាមួយ យឹម ទិត្យ ក្នុងកម្រិតដែលថា ត្រូវមានសិទ្ធិក្នុងការទទួលបាន ការសម្រេចស្ថាពរនៃរឿងក្តី[104]។ ប៉ុន្តែផ្ទុយទៅនឹងរឿងក្តី *Marini* ដែលគាត់សំអាងលើ[105] ក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ត្រូវបានរៀបចំរចនាសម្ព័ន្ធដើម្បីធានាបាននូវសច្ចភាពផ្លូវច្បាប់ និងការសម្រេចជាស្ថាពរអំពីបញ្ហានានា ក្នុងករណីដែលលក្ខខណ្ឌតម្រូវសំឡេងភាគច្រើនមិនអាចរកបាន ដោយការចែងថា

---

[101] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៥៤។

[102] សូមមើលបន្ថែមទៀត បណ្តឹងសាទុក្ខរបស់ ស.ព.អ ជើងទំព័រ ៩៩។

[103] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៥៥ *ដកស្រង់* ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា កថាខណ្ឌ ១០៥។

[104] ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ៩ *ដកស្រង់ ក្នុងចំណោមផ្សេងទៀត* រឿងក្តី *Frydlender* កថាខណ្ឌ ៤៥ និងរឿងក្តី *Multiplex ទល់នឹងប្រទេសក្រូអាត* សំណុំរឿងលេខ ៥៨១១២/០០ សាលក្រម ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៤៥។

[105] រឿងក្តី *Marini* កថាខណ្ឌ ១១៨។ *ផ្ទុយពី* ឯកសារ **D386** សំណើសុំបញ្ចប់ កថាខណ្ឌ ៩។

ជំហានបន្ទាប់ដែលសមស្រប គឺត្រូវបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងទៅ អ.ជ.ស.ដ[106]។

## IV. ដំណោះស្រាយដែលស្នើសុំ

32. សម្រាប់សំអាងហេតុដូចបានជម្រាបជូនខាងលើ សំណើសុំរបស់ យឹម ទិត្យ គួរត្រូវបាន បដិសេធចោល។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ | **លោកស្រី Brenda J. HOLLIS** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[106] សូមមើលបន្ថែមទៀត ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ៥២១-៥២៣, ៥៣៩ ទំព័រ ៣៥០ (ផ្នែកសម្រេចសេចក្តី)។